# គោលការណ៍ណែនាំអាស៊ាន
# ស្ដីពី
# ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម
# ពលករទេសន្តរប្រវេសន៍ ប្រកបដោយប្រសិទ្ធភាព

asean

one vision
one identity
one community

# គោលការណ៍ណែនាំអាស៊ាន
# ស្ដីពី
# ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម
# ពលករទេសន្តរប្រវេសក៍ ប្រកបដោយប្រសិទ្ធភាព


លេខាធិការដ្ឋានអាស៊ាន

ទីក្រុងហ្សាការតា

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៦៧។ រដ្ឋជាសមាជិករួមមាន ព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

លេខាធិការដ្ឋានអាស៊ានមានទីតាំងនៅក្នុងទីក្រុង ហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី។
សម្រាប់សំណួរសូមទំនាក់ទំនង៖
ផ្នែកទំនាក់ទំនងសហគមន៍ (CRD)
នៃលេខាធិការដ្ឋានអាស៊ាន
អាសយដ្ឋាន៖ 70A Jalan Sisingamangaraja
ហ្សាកាតា 12110, ឥណ្ឌូណេស៊ី
ទូរស័ព្ទ៖ (62 21) 724-3372, 726-2991
ទូរសារ៖ (62 21) 739-8234, 724-3504
អ៊ីមែល៖ public@asean.org

ទិន្នន័យកាតាឡុកនៃឯកសារបោះពុម្ពផ្សាយ

គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ប្រកបដោយប្រសិទ្ធភាពទីក្រុងហ្សាកាតា លេខាធិការដ្ឋានអាស៊ាន ខែវិច្ឆិកា ឆ្នាំ២០២០
331.544
១. អាស៊ាន – ការងារ – គោលការណ៍ណែនាំ
២. ការងារ – ការការពារ – ពលករទេសន្តរប្រវេសក៍

9 786025 798887

អាស៊ាន៖ សហគមន៍នៃឱកាសសម្រាប់ទាំងអស់គ្នា

អត្ថបទនៃឯកសារបោះពុម្ពផ្សាយអាចដកស្រង់ ឬបោះពុម្ពឡើងវិញ ដោយសេរី ដរាបណាមានការបញ្ជាក់ពីឈ្មោះឯកសារឱ្យបានត្រឹមត្រូវ ហើយសំណៅឯកសារដែលមានបញ្ចូល ឯកសារដែលត្រូវបានបោះពុម្ពឡើងវិញត្រូវផ្ញើទៅកាន់ផ្នែកទំនាក់ទំនងសហគមន៍ (CRD) នៃលេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាកាតា។

ព័ត៌មានទូទៅអំពីអាស៊ាន អាចរកបានតាមប្រព័ន្ធអនឡាញ ពីគេហទំព័ររបស់អាស៊ាន៖ www.asean.org

រក្សាសិទ្ធិដោយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ២០២០។
រក្សាសិទ្ធិគ្រប់បែបយ៉ាង។

Australian Aid    Canada    International Labour Organization

ការរៀបចំ៖ គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ប្រកបដោយប្រសិទ្ធភាពបានទទួលការគាំទ្រពីគម្រោងត្រីកោណក្នុងតំបន់អាស៊ាន ដែលជាភាពជាដៃគូរវាងអង្គការអន្តរជាតិខាងការងារ (ILO) ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) និងក្រសួងការបរទេសកាណាដា (GAC)។ ទស្សនៈយល់ឃើញដែលត្រូវបានលើកឡើងនៅក្នុងឯកសារនេះ មិនមែនសុទ្ធតែជាការយល់ឃើញរបស់ ILO និងរដ្ឋាភិបាលប្រទេសអូស្ត្រាលី ឬប្រទេសកាណាដានោះឡើយ។

# មាតិកា


I. **សេចក្តីផ្តើម** .................... ០១

II. **កម្មវត្ថុនៃគោលការណ៍ណែនាំនេះ** .................... ០៤

III. **អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធនៃគោលការណ៍ណែនាំនេះ** .................... ០៥

IV. **ប្រភព និងឯកសារយោង នៃគោលការណ៍ណែនាំនេះ** .................... ០៥

V. **គោលការណ៍ណែនាំទូទៅ** .................... ០៨

- V.១. ការផ្អែកលើមូលដ្ឋានសិទ្ធិ .................... ០៩
- V.២. គោលការណ៍នៃប្រព្រឹត្តកម្មដោយស្មើភាព .................... ១០
- V.៣. ការទទួលស្គាល់ពីប្រភេទខុសៗគ្នានៃពលករដែលធ្វើមាតុភូមិនិវត្តន៍ និងតម្រូវការរបស់ពួកគេ .................... ១១
- V.៤. ការគាំទ្រឱ្យចំក្រុមងាយរងគ្រោះ .................... ១២
- V.៥. ការគិតគូរយេនឌ័រ និងការឆ្លើយតបចំពោះយេនឌ័រ .................... ១២
- V.៦. ការផ្តោតលើសហគមន៍ .................... ១៣
- V.៧. តម្លាភាព និងសុចរិតភាព .................... ១៤
- V.៨. ភាពជាតំណាងនៃសំឡេងរបស់ពលករទេសន្តរប្រវេសន៍ .................... ១៤
- V៩. ការចូលរួមរបស់តួអង្គពាក់ព័ន្ធចម្រុះ .................... ១៥
- V.១០. គោលការណ៍នៃទំនួលខុសត្រូវរួម រវាងប្រទេសបញ្ជូន និងប្រទេសទទួល .................... ១៥
- V.១១. ការផ្អែកលើមូលដ្ឋានភស្តុតាង .................... ១៦

VI. **គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាពរបស់ពលករទេសន្តរប្រវេសន៍** .................... ១៦

- VI.១. ក្របខ័ណ្ឌគតិយុត្ត .................... ១៦

VI.១.១. ការរៀបចំ និងការធ្វើអោយប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជារួម និងយន្តការស្ថាប័ន ១៦

VI.១.២. ដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍៖ ជំហានសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយប្រសិទ្ធភាពចេញពីទស្សនៈរដ្ឋបញ្ជូន ................................. ១៨

VI.១.៣. ព័ត៌មាន និងប្រព័ន្ធទិន្នន័យអំពីពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ ................. ១៩

VI.១.៤. ការវាយតម្លៃលើតម្រូវការនៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសក៍ ........................... ២១

VI.២. សមាហរណកម្មសេដ្ឋកិច្ច ................................................ ២២

VI.៣. សមាហរណកម្មសង្គម និងវប្បធម៌ ..................................... ២៥

VI.៤. កិច្ចគាំពារសង្គម .............................................................. ២៦

**VII. យុទ្ធសាស្ត្រដែលអំណោយផល និងរួមចំណែកសម្រាប់ភាពជោគជ័យនៃកម្មវិធីសមាហរណកម្ម** ......................................................... ២៧

VII.១. បរិយាកាសសេដ្ឋកិច្ច នយោបាយ និងសង្គមជារួម ................. ២៧

VII.២. ដំណើរការមុនពេលចេញដំណើរ ......................................... ២៧

VII.៣. ក្រោយពេលទៅដល់ និងក្នុងអំឡុងពេលធ្វើការនៅក្រៅប្រទេស .... ២៨

**VIII. ការកសាងសមត្ថភាពនៃស្ថាប័ន និងដៃគូអនុវត្ត** .................................... ៣១

**IX. ការកៀរគរធនធានសម្រាប់សមាហរណកម្ម** ......................................... ៣២

**X. ការអនុវត្ត និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃគោលការណ៍ណែនាំអាស៊ាន** ..................................................................................... ៣៤

**ឧបសម្ព័ន្ធទី ១៖**
**សន្ទានុក្រម វាក្យស័ព្ទគន្លឹះ អមនឹងនិយមន័យ** ...................................... ៣៦

**ឧបសម្ព័ន្ធទី ២៖**
**តារាងសង្ខេបនៃការអនុវត្តប្រកបដោយសក្តានុពលរបស់អាស៊ាន និងអន្តរជាតិដែលបានជ្រើសរើស** ...................................................... ៤៣

# ពាក្យកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ACMW | ASEAN Committee on the Implementation of the ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers | គណៈកម្មការអាស៊ានលើការអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ |
| ACTIP | ASEAN Convention against Trafficking in Persons Especially Women and Children | អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ |
| AFML | ASEAN Forum on Migrant Labour | វេទិកាអាស៊ាន ស្ដីពីការងារទេសន្តរប្រវេសន៍ |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEAN Consensus | ASEAN Consensus on the Protection and Promotion of the Rights of Migrant Workers, 2017 | ឯកច្ឆន្ទភាពអាស៊ានស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០១៧ |

| | | |
|---|---|---|
| Cebu Declaration | ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers, 2007 | សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០០៧ |
| CEDAW | Convention on the Elimination of All forms of Discrimination Against Women | អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| GCM | Global Compact on Safe, Orderly and Regular Migration | កតិកាសញ្ញាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ |
| ICRMW | International Convention on the Protection of the Rights of All Migrant Workers and Members of their Families | អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសក៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ |
| ILO | International Labour Organization | អង្គការអន្តរជាតិខាងការងារ |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UN | United Nations | អង្គការសហប្រជាជាតិ |

# I. សេចក្តីផ្តើម

## បរិបទជារួម

១. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) គឺជាទីផ្សារការងារថ្នាក់តំបន់ ដែលមានពលករទេសន្តរប្រវេសក៍រាប់លាននាក់ ផ្លាស់ទីទាំងក្នុងតំបន់នេះ និងទៅតំបន់ដទៃទៀត។ ភាគច្រើននៃពលករទេសន្តរប្រវេសន៍ទាំងនេះ គឺជាពលករដែលមានជំនាញទាប ដែលពួកគេធ្វើទេសន្តរប្រវេសន៍ដើម្បីរកការងារដែលមានកិច្ចសន្យារយៈពេលខ្លីធ្វើជាបណ្តោះអាសន្ន។ ដូច្នេះ ការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេទៅប្រទេសកំណើតនៅឆ្នាំណាមួយអាចមានចំនួនច្រើន។ នៅក្នុងករណីដែលពុំមានក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយសម្រាប់ផ្តល់សេវាគាំទ្រ ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញ អាចជួបនឹងបញ្ហាប្រឈមជាច្រើនដែលអាចប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេ ក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍កំណើតរបស់ពួកគេវិញ ការដោះស្រាយបញ្ហាប្រឈមផ្នែកផ្លូវចិត្តសង្គម ការស្វែងរកឱកាសប្រកបមុខរបរចិញ្ចឹមជីវិតប្រកបដោយចីរភាព ឬការធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារការងារ។ កង្វះគោលនយោបាយ និងជម្រើសនៃការធ្វើសមាហរណកម្មគ្រប់គ្រាន់ អាចនាំឱ្យមានការខាតបង់អត្ថប្រយោជន៍ដល់ពលករទេសន្តរប្រវេសក៍ សហគមន៍របស់ពួកគេ និងសង្គមទាំងមូល។

២. លិខិតូបករណ៍របស់អាស៊ាន ស្តីពីទេសន្តរប្រវេសន៍ជាច្រើន បានបញ្ចូលការប្តេជ្ញាចិត្ត ដែលត្រូវអនុវត្តដោយរដ្ឋជាសមាជិកអាស៊ានជុំវិញការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍។ លិខិតូបករណ៍ទាំងនេះ ផ្តោតសំខាន់លើការទទួលខុសត្រូវរបស់ប្រទេសបញ្ជូន។

២.១. មាត្រា ១៣ នៃសេចក្តីថ្លែងការណ៍អាស៊ានឆ្នាំ២០០៧ ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ (ដែលចាប់ពីចំណុចនេះតទៅហៅថា "សេចក្តីថ្លែងការណ៍សេប៊ូ") តម្រូវឱ្យរដ្ឋបញ្ជូន៖

> "រៀបចំគោលនយោបាយ និងនីតិវិធី ដើម្បីផ្តល់ការសម្របសម្រួលការធ្វើទេសន្តរប្រវេសន៍របស់ពលករ មានដូចជា

ការជ្រើសរើសពលករ ការត្រៀមរៀបចំសម្រាប់បញ្ជូនពលករទៅក្រៅប្រទេស និងការការពារពលករទេសន្តរប្រវេសន៍នៅពេលដែលពួកគេស្ថិតនៅក្រៅប្រទេស ក៏ដូចជាសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មចូលក្នុងប្រទេសដើមវិញ"។

មាត្រា ១៦ នៃសេចក្ដីថ្លែងការណ៍សេប៊ូ តម្រូវឱ្យអាស៊ានៈ

"បង្កើត និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស និងកម្មវិធីសមាហរណកម្មសម្រាប់ពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសដើមរបស់ពួកគេ"។

២.២. មាត្រា ២៦ នៃឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ដែលចាប់ពីចំណុចនេះតទៅ "ហៅថាឯកច្ឆន្ទភាពអាស៊ាន") លើកឡើងថាៈ

"រដ្ឋបញ្ជូនត្រូវអភិវឌ្ឍកម្មវិធីសមាហរណកម្ម ឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់ពលករទេសន្តរប្រវេសន៍និងសមាជិកគ្រួសាររបស់ពួកគេ ដែលបានធ្វើមាតុភូមិនិវត្តន៍ ក៏ដូចជាកម្មវិធីផ្ដល់ការងារឱ្យធ្វើ ដោយគិតគូរអំពីជំនាញដែលពួកគេទទួលបានពីក្រៅប្រទេស"។

លើសពីនេះ មាត្រា ២៨ នៃឯកច្ឆន្ទភាពអាស៊ាន ចែងថាៈ

"រដ្ឋបញ្ជូនត្រូវធានាឱ្យបាននូវសិទ្ធិពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ក្នុងការបង្កើតសមាគម ការចូលរួមក្នុងការបង្កើតគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ និងការទទួលបានសេវាផ្សេងៗ សម្រាប់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិនៃរដ្ឋបញ្ជូន"។

៣. កិច្ចប្រជុំភាគច្រើននៃវេទិកាអាស៊ានស្តីពីពលករទេសន្តរប្រវេសន៍ (AFML) ជាពិសេសវេទិកាអាស៊ានស្តីពីពលករទេសន្តរប្រវេសន៍ (AFML) លើកទី៤

បានដាក់ចេញនូវអនុសាសន៍ជាច្រើនស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍។ វេទិកា AFML លើកទី ៤ (ដែលបានធ្វើឡើងកាលពីថ្ងៃ២៤-២៥ ខែតុលា ឆ្នាំ២០១១ នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី) បានអំពាវនាវជាពិសេសឱ្យមាន "ការរៀបចំគោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាព" (អនុសាសន៍លេខ ១៤)។

៤. បន្ទាប់ពីបានដាក់ចេញអនុសាសន៍ក្នុងវេទិកា AFML លើកទី ៤ គម្រោងមួយត្រូវបានរៀបចំឡើង សម្រាប់អនុវត្តផែនការការងារ ឆ្នាំ២០១៦-២០២០ របស់គណៈកម្មការអាស៊ានទទួលបន្ទុកអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ (ACMW) ក្រោមការដឹកនាំរបស់ប្រទេសឥណ្ឌូណេស៊ី។ សិក្ខាសាលាអាស៊ាន ស្តីពីកម្មវិធីសមាហរណកម្មសម្រាប់ពលករទេសន្តរប្រវេសក៍ ដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានរៀបចំដោយប្រទេសឥណ្ឌូណេស៊ី នៅថ្ងៃទី២៧-២៨ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុង Yogyakarta[១] ដើម្បីរៀបចំមាតិកានៃគោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ ប្រកបដោយប្រសិទ្ធភាព (ដែលចាប់ពីចំណុចនេះតទៅហៅថាគោលការណ៍ណែនាំ)។ មាតិកានេះ ត្រូវបានពិនិត្យ និងទទួលបានការឯកភាពពីរដ្ឋាភិបាល អង្គការនិយោជក អង្គការនិយោជិត និងអង្គការសង្គមស៊ីវិល ដែលបានចូលរួមក្នុងសិក្ខាសាលានេះ។

៥. សិក្ខាសាលាអាស៊ាន ស្តីពីកម្មវិធីសមាហរណកម្មសម្រាប់ពលករទេសន្តរប្រវេសក៍ ដែលធ្វើមាតុភូមិនិវត្តន៍ ដែលមានខ្លឹមសារដូចបានបង្ហាញជូនខាងលើ បានឯកភាពឱ្យមានការរៀបចំគោលការណ៍ណែនាំនេះឡើង។ មាតិកាគោលការណ៍ណែនាំ ដែលត្រូវបានកែសម្រួលឡើងវិញ និងដែលបានទទួលការអនុម័ត ត្រូវបានរៀបចំឡើង ដោយផ្អែកតាមធាតុចូលទទួលបានពីរដ្ឋាភិបាល អង្គការនិយោជក អង្គការនិយោជិត និងអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងសិក្ខាសាលានេះ។

---

១ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយក្រសួងការងារនៃរដ្ឋាភិបាលឥណ្ឌូណេស៊ី ដោយមានការគាំទ្រពីលេខាធិការដ្ឋានអាស៊ាន និងកម្មវិធីត្រីកោណអាស៊ាននៃអង្គការអន្តរជាតិខាងការងារ-ដែលជាភាពជាដៃគូររវាងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) និងក្រសួងការបរទេសកាណាដា (GAC) និង ILO។

៦. គោលការណ៍ណែនាំនេះ ផ្តោតលើគោលការណ៍សំខាន់ៗ ការប្តេជ្ញាចិត្ត ដែលត្រូវអនុវត្តជាសកម្មភាព និងការអនុវត្តល្អពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍។ គោលការណ៍ណែនាំនេះ មានមូលដ្ឋានគាំទ្រពីឯកសារទេស្សនទាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសក៍ ដោយផ្តោតជាពិសេសលើរដ្ឋជាសមាជិកអាស៊ាន ដែលត្រូវបានផ្សព្វផ្សាយនៅក្នុងសិក្ខាសាលានោះ។

## II. **កម្មវត្ថុនៃគោលការណ៍ណែនាំនេះ**

៧. គោលការណ៍ណែនាំនេះ មានកម្មវត្ថុ ដូចខាងក្រោម៖

៧.១. ដាក់ចេញនូវគោលការណ៍ណែនាំ សម្រាប់រដ្ឋជាសមាជិកអាស៊ាន ស្តីពីគោលនយោបាយ យន្តការស្ថាប័ន ព្រមទាំងកម្មវិធីនិងសេវាកម្ម ដែលចាំបាច់ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម របស់ពលករទេសន្តរប្រវេសក៍ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដោយស្របតាមស្តង់ដារអន្តរជាតិ និងស្តង់ដារអង្គការអន្តរជាតិខាងការងារ និងឯកច្ឆន្ទភាពអាស៊ានដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិនៃរដ្ឋសមាជិកអាស៊ាន ដែលមានជាធរមាន។

៧.២. ផ្តល់ជាមគ្គុទេសក៍ដល់រដ្ឋជាសមាជិកអាស៊ាន និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ សម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌសកម្មភាព ស្តីពីសមាហរណកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយចីរភាព នៅថ្នាក់ជាតិ កម្រិតទ្វេភាគី និងថ្នាក់តំបន់។

៧.៣. ពង្រឹងភាពជាដៃគូ ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍។

៧.៤. ផ្តួចផ្តើម និងបន្តលើកទឹកចិត្តយ៉ាងសកម្មដល់រដ្ឋាភិបាល អង្គការនិយោជក អង្គការនិយោជិត ព្រមទាំងសង្គមស៊ីវិល និងតួអង្គពាក់ព័ន្ធ

នានា ក្នុងការបញ្ចូលគោលការណ៍ណែនាំនេះទៅក្នុងកិច្ចខិតខំប្រឹងប្រែងនៃការសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសន៍។

## III. អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធនៃគោលការណ៍ណែនាំនេះ

៨. គោលការណ៍ណែនាំនេះមានគោលបំណងផ្តល់ជាការណែនាំដល់តួអង្គពាក់ព័ន្ធសំខាន់ៗដែលធ្វើការងារទាក់ទងនឹងការធ្វើមាតុភូមិនិវត្តន៍និងសមាហរណកម្មពលករទេសន្តរប្រវេសន៍ នៅក្នុងរដ្ឋជាសមាជិកអាស៊ាន ជាពិសេស៖

- រដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ាននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- អង្គការនិយោជក
- អង្គការនិយោជិត
- ពលករទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ
- អង្គការសង្គមស៊ីវិល
- ទីភ្នាក់ងារមុខរបរ និងការងារឯកជន/ទីភ្នាក់ងារជ្រើសរើសឯកជន
- វិស័យឯកជន (រួមទាំងសហគ្រាសខ្នាតតូចនិងមធ្យម) និងនិយោជកនៅក្នុងរដ្ឋបញ្ជូន និងរដ្ឋទទួល
- រដ្ឋដែលជាដៃគូរបស់អាស៊ាន និង
- ដៃគូអភិវឌ្ឍន៍ (ឧទាហរណ៍ អ្នកផ្តល់ជំនួយ)

## IV. ប្រភព និងឯកសារយោង នៃគោលការណ៍ណែនាំនេះ

៩. លិខិតូបករណ៍ និងប្រភពឯកសារខាងក្រោម ត្រូវបានចាត់ទុកថាជាប្រភពឯកសារដែលមានប្រយោជន៍សម្រាប់ធ្វើជាមូលដ្ឋានដល់ការរៀបចំគោល - ការណ៍ណែនាំនេះ និងសម្រាប់ការអនុវត្តបន្ត ដោយរដ្ឋជាសមាជិកអាស៊ាន និងអ្នកពាក់ព័ន្ធដទៃទៀត។

៩.១. លិខិតូបករណ៍ របស់អាស៊ាន៖

- សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០០៧ (សេចក្តីថ្លែងការណ៍សេប៊ូ)
- ឯកច្ឆន្ទភាពអាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០១៧ (ឯកច្ឆន្ទភាពអាស៊ាន)
- សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គមនិងក្របខ័ណ្ឌ និងផែនការសកម្មភាពថ្នាក់តំបន់
- អនុសញ្ញាអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (ACTIP)
- សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីសិទ្ធិមនុស្ស
- ធម្មនុញ្ញអាស៊ាន
- ចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ ២០២៥
- គោលការណ៍ណែនាំអាស៊ាន ស្តីពីទំនួលខុសត្រូវសង្គមរបស់សហគ្រាស លើកម្លាំងពលកម្ម
- អនុសាសន៍នៃវេទិកាអាស៊ាន ស្តីពីពលករទេសន្តរប្រវេសក៍ (AFML)

៩.២. លិខិតូបករណ៍សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិខាងការងារ ដែលពាក់ព័ន្ធជាពិសេសជាមួយនឹងពលករទេសន្តរប្រវេសក៍៖

- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស
- អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW)
- អនុសញ្ញាអន្តរជាតិ ស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសក៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ICRMW)
- ស្តង់ដារការងារស្នូលរបស់អង្គការអន្តរជាតិខាងការងារ ពាក់ព័ន្ធនឹងសេរីភាពនៃការបង្កើតសមាគម ការងារដោយបង្ខំ ពលកម្មកុមារ និងការរើសអើង។

៩.៣. ស្តង់ដារការងារដែលពាក់ព័ន្ធ និងក្របខ័ណ្ឌមិនចងកាតព្វកិច្ចរបស់អង្គការអន្តរជាតិខាងការងារៈ

- អនុសញ្ញា ILO ស្តីពីទេសន្តរប្រវេសន៍ការងារ (កែសម្រួលឡើងវិញ) ឆ្នាំ១៩៤៩ (លេខ ៩៧)
- អនុសញ្ញា ILO ស្តីពីពលករទេសន្តរប្រវេសក៍ (បញ្ញត្តិបន្ថែម) ឆ្នាំ ១៩៧៥ (លេខ ១៤៣)
- អនុសញ្ញា ILO ស្តីពីទីភ្នាក់ងារជ្រើសរើសពលករ ឆ្នាំ១៩៩៧ (លេខ ១៨១)
- អនុសញ្ញា ILO ស្តីពីកម្មករការងារផ្ទះ ឆ្នាំ២០១១ (លេខ ១៨៩)
- អនុសញ្ញា ILO ស្តីពីការងារ ក្នុងវិស័យនេសាទ ឆ្នាំ២០០៧ (លេខ ១៨៨)
- ស្តង់ដារការងារទាំងអស់ផ្សេងទៀតរបស់អង្គការ ILO ពាក់ព័ន្ធនឹងការងារ រួមបញ្ចូលទាំងស្តង់ដារស្តីពីសន្តិសុខសង្គម លក្ខខណ្ឌការងារ គោលនយោបាយមុខរបរនិងការងារ អធិការកិច្ចការងារ សុខភាពនិងសុវត្ថិភាពការងារ ។ល។
- ក្របខ័ណ្ឌពហុភាគីរបស់អង្គការ ILO ស្តីពីទេសន្តរប្រវេសន៍ការងារ
- គោលការណ៍ទូទៅ និងគោលការណ៍ណែនាំប្រតិបត្តិរបស់អង្គការ ILO ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងការកំណត់ថ្លៃសេវា និងថ្លៃចំណាយពាក់ព័ន្ធនឹងការជ្រើសរើសពលករ
- របៀបវារៈការងារសមរម្យរបស់អង្គការ ILO
- សេចក្តីថ្លែងការណ៍សហស្សវត្សរ៍របស់អង្គការ ILO ស្តីពីអនាគតការងារ
- សេចក្តីថ្លែងការណ៍បាលី ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី ១៦ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក នៅទីក្រុងបាលី ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃ៩ ខែ ធ្នូ ឆ្នាំ២០១៦។

៩.៤. ក្របខ័ណ្ឌសកលស្តីពីការអភិវឌ្ឍ និងទេសន្តរប្រវេសន៍៖

- របៀបវារៈអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ឆ្នាំ២០១៨(GCM)
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១១ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ អនុវត្តក្របខ័ណ្ឌការពារ គោរព និងផ្តល់សំណងរបស់អង្គការសហប្រជាជាតិ។

## V. គោលការណ៍ណែនាំទូទៅ

១០. វាគឺជាការអនុវត្តស្តង់ដារ ដែលត្រូវរៀបរាប់ពីគោលការណ៍ទូទៅ មុននឹងបង្ហាញពីគោលការណ៍ណែនាំប្រតិបត្តិ សម្រាប់សកម្មភាពអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍នេះ។ គោលការណ៍ទូទៅ ត្រូវបានដកស្រង់ចេញពីប្រភពជាច្រើន ដូចជា លិខិតូបករណ៍អន្តរជាតិ ស្តង់ដារ និងក្របខ័ណ្ឌរបស់អង្គការអន្តរជាតិខាងការងារ ក្របខ័ណ្ឌសកល និងក្របខ័ណ្ឌអាស៊ាន ដូចដែលបានកំណត់នៅផ្នែកទី IV ខាងលើ។ គោលការណ៍ណែនាំទូទៅខាងក្រោមនេះ ផ្តល់នូវក្របខ័ណ្ឌ និងមូលដ្ឋានរួម សម្រាប់គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ ប្រកបដោយប្រសិទ្ធភាព និងការរៀបចំយុទ្ធសាស្រ្ត ដើម្បីរួមចំណែកដល់ការអនុវត្តគោលការណ៍ណែនាំនេះ ដូចដែលបានដាក់ចេញនៅក្នុងផ្នែកទី VI និង VII ។ ការគោរពតាមគោលការណ៍ទូទៅ អាចធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាផ្នែកគោលនយោបាយ និងវិធានការនានា ដែលត្រូវបានរំលេចឡើងក្រោមគោលការណ៍ណែនាំនេះ។ គោលការណ៍ណែនាំនេះ បង្ហាញពីវិធានការអនុវត្ត និងកិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដែលអាចរៀបចំនៅក្នុងក្របខ័ណ្ឌរួមនៃស្តង់ដារអន្តរជាតិ និងស្តង់ដារថ្នាក់តំបន់ផ្សេងៗទៀតបាន។

## VI. ការឈរលើមូលដ្ឋានសិទ្ធិ

១១. រាល់គោលនយោបាយ និងកម្មវិធីទាំងអស់ គួរឈរលើមូលដ្ឋានសិទ្ធិ ពោលគឺត្រូវគោរពសិទ្ធិមនុស្ស និងសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី និងបុរស និងគ្រួសាររបស់ពួកគេ ស្របតាមលិខិតូបករណ៍អន្តរជាតិ និងលិខិតូបករណ៍អាស៊ាន។ គោលការណ៍ទូទៅទី៤ នៃសេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស ចែងថា៖

> "សិទ្ធិរបស់ស្ត្រី កុមារ ជនចាស់ជរា ជនមានពិការភាព ពលករទេសន្តរប្រវេសន៍ ក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច គឺជាផ្នែកដែលមិនអាចដកហូតបាន មានសារៈសំខាន់ និងមិនអាចផ្តាច់ចេញបាននៃសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្ស"។

១២. គោលការណ៍ទូទៅទី ១ នៃសេចក្តីថ្លែងការណ៍សេប៊ូ ឆ្នាំ២០០៧ ចែងថា៖

> "ទាំងរដ្ឋទទួល និងរដ្ឋបញ្ជូន ត្រូវពង្រឹងសសរស្តម្ភនយោបាយ សេដ្ឋកិច្ច និងសង្គមវប្បធម៌នៃសហគមន៍អាស៊ាន តាមរយៈការលើកកម្ពស់សក្តានុពល និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ឱ្យបានពេញលេញ នៅក្នុងបរិយាកាស ដែលផ្តល់នូវសេរីភាព សមធម៌ និងស្ថិរភាព ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនៃប្រទេសជាសមាជិកអាស៊ាន"។ឯកច្ឆន្ទភាពអាស៊ានតម្រូវឱ្យរដ្ឋជាសមាជិកអាស៊ានគោរពសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ ព្រមទាំងធានាឱ្យមានប្រព្រឹត្តកម្មដោយស្មើភាពដល់ពួកគេនៅកន្លែងធ្វើការ។[២]

១៣. វេទិកាអាស៊ានស្តីពីពលករទេសន្តរប្រវេសន៍ AFML លើកទី៤ បានផ្តល់ជាអនុសាសន៍ដូចតទៅ "ធានាថា កម្មវិធីមាតុភូមិនិវត្តន៍ និងសមាហរណកម្មត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ចីរភាព និងឈរលើគោលការណ៍សិទ្ធិ ដោយមានការចូលរួមពីដៃគូត្រីភាគី និងអង្គការសង្គមស៊ីវិល"។

---

២ ប្រការ ៧ នៃឯកច្ឆន្ទភាពអាស៊ាន លើកឡើងថា "ប្រព្រឹត្តកម្មដោយស្មើភាព សំដៅដល់ការប្រព្រឹត្តប្រកបដោយភាពយុត្តិធម៌ និងសមហេតុផល ដែលអនុវត្តទៅលើពលករទេសន្តរប្រវេសន៍នៅកន្លែងធ្វើការ ដោយគោរពនូវលក្ខខណ្ឌការងារ សុវត្ថិភាពការងារ និងលទ្ធភាពទទួលបានប្រភពជំនួយក្នុងពេលធ្វើការងារ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិជាធរមាននៃរដ្ឋទទួល"។

១៤. ការផ្តល់សច្ចាប័នដល់លិខិតូបករណ៍អន្តរជាតិស្តីពីពលករទេសន្តរប្រវេសក៍ នឹងបន្តពង្រឹងការប្តេជ្ញាក្នុងការបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចលើទេសន្តរប្រវេសន៍ ក៏ដូចជាការលើកកម្ពស់ និងការការពារសិទ្ធិពលករទេសន្តរប្រវេសក៍។ គោលការណ៍សំខាន់នៃលិខិតូបករណ៍ទាំងនេះ រួមមានប្រព្រឹត្តកម្មដោយស្មើភាព និងឱកាសស្មើភាព ព្រមទាំងការមិនរើសអើង។ ប្រទេសហ្វីលីពីនបានផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិទាំង ៣ ស្តីពីពលករទេសន្តរប្រវេសក៍ និងអនុសញ្ញាអង្គការ ILO ស្តីពីកម្មករការងារតាមផ្ទះ ឆ្នាំ២០១១ (លេខ ១៨៩) ខណៈពេលដែលប្រទេសឥណ្ឌូណេស៊ីបានផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិ ស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសក៍គ្រប់រូប និងគ្រួសាររបស់ពួកគេ។ រដ្ឋសាបានៃប្រទេសម៉ាឡេស៊ីបានផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការ ILO ស្តីពីទេសន្តរប្រវេសន៍ដើម្បីការងារ (កែសម្រួល) ឆ្នាំ១៩៤៩ (លេខ ៩៧)។ រដ្ឋជាសមាជិកអាស៊ានទាំងអស់សុទ្ធតែបានផ្តល់សច្ចាប័ន ដល់លិខិតូបករណ៍សិទ្ធិមនុស្សជាច្រើនរបស់អង្គការសហប្រជាជាតិ ក៏ដូចជាអនុសញ្ញាស្នូលរបស់ អង្គការ ILO និងអនុសញ្ញាដទៃទៀត។

## *V.២. គោលការណ៍នៃប្រព្រឹត្តកម្មដោយស្មើភាព*

១៥. សេរីភាពពីការរើសអើង គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងជាផ្នែកដ៏សំខាន់ និងចាំបាច់សម្រាប់លើកកម្ពស់ការងារសមរម្យ ដែលផ្តល់លទ្ធភាពឱ្យពលករទេសន្តរប្រវេសក៍អភិវឌ្ឍសក្តានុពលរបស់ពួកគេឱ្យបានពេញលេញ។ លិខិតូបករណ៍របស់អង្គការ ILO ហាមប្រាមមិនឱ្យមានការបែងចែក ការផាត់ចេញ ឬការផ្តល់អាទិភាព ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ទស្សនៈនយោបាយ ជាតិកំណើត ឬដើមកំណើតសង្គម ដែលនាំឱ្យមានមោឃភាព ឬធ្វើឱ្យប៉ះពាល់ដល់ឱកាស ឬប្រព្រឹត្តកម្មដោយស្មើភាពមកលើពួកគេក្នុងការងារ ឬការប្រកបមុខរបរ។[៣] សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលអន្តរជាតិ ផ្តល់នូវក្របខ័ណ្ឌទូលំទូលាយមួយ សម្រាប់ជំរុញមិនឱ្យមានការរើសអើង និងការការពារសិទ្ធិមនុស្ស ដល់មនុស្សគ្រប់រូប ដោយរាប់បញ្ចូលទាំងពលករទេសន្តរប្រវេសក៍ទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងសិទ្ធិរបស់ពួកគេនៅកន្លែងធ្វើការ។

៣ អនុសញ្ញា របស់ ILO ស្តីពីការរើសអើង (ក្នុងការងារ និងការប្រកបមុខរបរ) ឆ្នាំ ១៩៥៨ (លេខ ១១១)។

ដូច្នេះហើយពលករទេសន្តរប្រវេសន៍គួរទទួលបានប្រព្រឹត្តកម្មដោយស្មើភាព ទាំងនៅក្នុងរដ្ឋទទួល និងរដ្ឋបញ្ជូន។

១៦. គន្លឹះដើម្បីទទួលបានជោគជ័យក្នុងការលើកកម្ពស់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មដោយពុំមានការរើសអើង និងប្រព្រឹត្តកម្មដោយស្មើភាព នៅក្នុងទីផ្សារការងារ គឺត្រូវជំរុញឱ្យមានការចូលរួមឱ្យបានសកម្មពីសំណាក់ អង្គការនិយោជក អង្គការនិយោជិត ពលករទេសន្តរប្រវេសន៍ ព្រមទាំងតួអង្គពាក់ព័ន្ធដទៃទៀត រួមទាំងសមាគមទីភ្នាក់ងារជ្រើសរើសពលករឯកជនផងដែរ។

## *V.៣. ការទទួលស្គាល់ពីប្រភេទខុសៗគ្នានៃពលករដែលធ្វើមាតុភូមិនិវត្តន៍ និងតម្រូវការរបស់ពួកគេ*

១៧. ពលករទេសន្តរប្រវេសន៍ធ្វើមាតុភូមិនិវត្តន៍ ក្រោមលក្ខខណ្ឌខុសៗគ្នា និងដោយសារមូលហេតុជាច្រើន ដូចជាៈ ការសម្រេចគោលដៅ ឬចំណុចដៅនៃការធ្វើទេសន្តរប្រវេសន៍របស់ពួកគេប្រកបដោយជោគជ័យ ការចូលនិវត្តន៍ ការពុំបានទទួលជោគជ័យ ឬការពុំអាចធ្វើសមាហរណកម្មនៅក្នុងប្រទេសគោលដៅ ការផុតរលត់នៃកិច្ចសន្យា ការងារបណ្តោះអាសន្ន ហេតុផលគ្រួសារ ស្ថានភាពនៅក្នុងប្រទេសកំណើតមានភាពល្អប្រសើរ គិតចាប់តាំងពីពេលដែលពួកគេចាកចេញ និងការបណ្តេញចេញ។ល។ ក្នុងវដ្តទេសន្តរប្រវេសន៍បណ្តោះអាសន្នដែលកើតមានច្រើន នៅក្នុងប្រទេសអាស៊ី និងប្រទេសមជ្ឈិមបូព៌ា ពលករទេសន្តរប្រវេសន៍ត្រូវវិលត្រឡប់ទៅប្រទេសកំណើតវិញ នៅពេលចប់កិច្ចសន្យា។ ពលករទេសន្តរប្រវេសន៍មួយចំនួនបានត្រៀមខ្លួនយ៉ាងល្អសម្រាប់ធ្វើសមាហរណកម្ម ដោយមានការជួយជ្រោមជ្រែងតិចតួចបំផុតពីរដ្ឋាភិបាល ខណៈពេលដែលពលករមួយចំនួនទៀត អាចធ្វើមាតុភូមិនិវត្តន៍នៅក្នុងស្ថានភាពពិបាក ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស។ ដូច្នេះ កម្មវិធីសមាហរណកម្មតម្រូវឱ្យមានការដាក់បញ្ចូលពីតម្រូវការផ្សេងៗគ្នារបស់ពួកគេ។

១៨. រដ្ឋបញ្ជូន និងរដ្ឋទទួល គួរលើកកម្ពស់ លក្ខខណ្ឌសម្រាប់ពលករទេសន្តរប្រវេសន៍ ដើម្បីឱ្យពួកគេអាចវិលត្រឡប់ដោយស្ម័គ្រចិត្ត ទៅតាមជម្រើសផ្ទាល់

ខ្លួនរបស់ពួកគេ ព្រោះថា ការរៀបចំបែបនេះ រួមចំណែកធ្វើឱ្យពួកគេត្រៀមខ្លួនបានកាន់តែល្អ សម្រាប់ធ្វើមាតុភូមិនិវត្តន៍ និងផ្តល់ឱ្យពួកគេនូវជម្រើស ឬសេរីភាពក្នុងការរៀបចំការធ្វើសមាហរណកម្មរបស់ពួកគេ។

### V.៤. ការគាំទ្រឱ្យចំក្រុមងាយរងគ្រោះ

១៩. គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ត្រូវឆ្លើយតបចំពោះហានិភ័យ និងចំពោះភាពងាយរងគ្រោះរបស់ពួកគេ ដែលពលករទេសន្តរប្រវេសក៍ផ្សេងៗគ្នាកំពុងជួបប្រទះ។ ពលករទេសន្តរប្រវេសក៍អាចស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ និងត្រូវការការពារ និងជំនួយនៅដំណាក់កាលផ្សេងៗគ្នាក្នុងការធ្វើទេសន្តរប្រវេសន៍របស់ពួកគេ ដូចជា នៅដំណាក់កាលឆ្លងកាត់ ពេលទៅដល់ប្រទេសគោលដៅ ក្នុងអំឡុងពេលធ្វើការនៅក្នុងប្រទេសគោលដៅ និងនៅពេលត្រឡប់មកប្រទេសកំណើតវិញ។ ជាទូទៅ ពលករទេសន្តរប្រវេសក៍ជាស្ត្រី ជាពិសេសអ្នកធ្វើការតាមផ្ទះ និងពលករទេសន្តរប្រវេសក៍ ដែលស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ ឬមិនផ្លូវការ អាចងាយរងគ្រោះខ្លាំង និងងាយទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ច។ តួអង្គពាក់ព័ន្ធ រាប់បញ្ចូលទាំងភ្នាក់ងាររដ្ឋាភិបាល ដែលមានសមត្ថកិច្ចដាក់លាក់លើបញ្ហានេះ អាចមានសមត្ថកិច្ចក្នុងការពិនិត្យ ដោះស្រាយ និងឆ្លើយតបទៅកាន់តម្រូវការរបស់ពួកគេ។

### V.៥. ការគិតគូរយេនឌ័រ និងការឆ្លើយតបចំពោះយេនឌ័រ

២០. ការគិតគូរពីយេនឌ័រ មានន័យថាជាការដឹងពីតម្រូវការ តួនាទី និងការទទួលខុសត្រូវ ផ្សេងៗគ្នារបស់ស្ត្រី និងបុរស ក៏ដូចជាឥទ្ធិពលដែលកត្តាទាំងនេះអាចមានទៅលើលទ្ធផលទទួលបាន និងការគ្រប់គ្រងធនធាន និងអត្ថប្រយោជន៍របស់ពួកគេ ទៅតាមកម្រិតផ្សេងៗគ្នា។ ការឆ្លើយតបចំពោះតម្រូវការយេនឌ័រ គឺមានវិសាលភាពលើសពីការវិនិច្ឆ័យ និងការយល់ឃើញជាក់ស្តែងនៃគម្លាតយេនឌ័រ ពោលគឺត្រូវមានការដាក់ចេញនូវគោលនយោបាយ សកម្មភាព និងគំនិតផ្តួចផ្តើម សំដៅឆ្លើយតប និងដោះស្រាយបញ្ហាវិសមភាពពាក់ព័ន្ធនឹងយេនឌ័រ។

២១. ដោយហេតុថាពលករទេសន្តរប្រវេសក៍ជាស្ត្រី និងបុរស អាចជួបប្រទះបញ្ហាខុសៗគ្នា នៅក្នុងវដ្តទេសន្តរប្រវេសន៍របស់ពួកគេ អ្នកតាក់តែងគោលនយោបាយនៅក្នុងតំបន់អាស៊ាន និងតួអង្គពាក់ព័ន្ធដទៃទៀត គួរខិតខំបញ្ជ្រាបការគិតគូរពីយេនឌ័រទៅក្នុងគ្រប់កិច្ចអន្តរាគមន៍ទាំងអស់ ដែលពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម។ ប្រការ ១ (ង) នៃឯកច្ឆន្ទភាពអាស៊ាន លើកឡើងថា រដ្ឋជាសមាជិកអាស៊ាន ត្រូវលើកកម្ពស់ប្រព្រឹត្តកម្មដោយស្មើភាពពាក់ព័ន្ធនឹងយេនឌ័រ ។ល។ អនុសាសន៍ទី១៩ នៃវេទិកាអាស៊ានស្តីពីពលករទេសន្តរប្រវេសក៍ លើកទី ៥ បានអំពាវនាវឱ្យមានការធ្វើសមាហរណកម្មដែលគិតគូរពីតម្រូវការយេនឌ័រ។ល។

### *V.៦. ការផ្តោតលើសហគមន៍*

២២. ពលករទេសន្តរប្រវេសក៍ ជាទូទៅធ្វើដំណើរចេញពីសហគមន៍កំណើតរបស់ពួកគេ ហើយជារឿយៗក៏វិលត្រឡប់ទៅសហគមន៍កំណើតរបស់ពួកគេវិញដែរ។ ដូច្នេះការសម្របសម្រួលដល់ការធ្វើសមាហរណកម្ម តម្រូវឱ្យកម្មវិធីនានាផ្តោតលើពលករដែលធ្វើមាតុភូមិនិវត្តន៍ផង និងលើសហគមន៍កំណើតដែលពួកគេត្រូវត្រឡប់ទៅវិញផង។ សហគមន៍ទាំងនេះអាចខ្វះធនធានសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ជួយទ្រទ្រង់ដល់ការរស់នៅរបស់ពលករទេសន្តរប្រវេសក៍។ ប្រសិនបើពលករទេសន្តរប្រវេសក៍ទទួលបានជំនួយ តែសមាជិកសហគមន៍របស់ពួកគេពុំបានទទួលជំនួយទេនោះ គេអាចយល់ឃើញថាពលករទាំងនោះបានទទួលការយកចិត្តទុកដាក់ ជាពិសេសខុសពីអ្នកដទៃទៀត ដែលកត្តានេះអាចបង្កើតឱ្យមានភាពតានតឹង ឬធ្វើឱ្យភាពតានតឹងដែលមានស្រាប់រួចទៅហើយនោះ កាន់តែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត។ កតិកាសញ្ញាសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព របៀបរៀប និងស្របច្បាប់ (GCM) ជំរុញឱ្យប្រទេសនានា "កំណត់ និងឆ្លើយតបចំពោះតម្រូវការរបស់សហគមន៍ដែលពលករទេសន្តរប្រវេសក៍ត្រឡប់ទៅវិញ តាមរយៈការបញ្ចូលខ្លឹមសារពាក់ព័ន្ធទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលដ្ឋាន ផែនការហេដ្ឋារចនាសម្ព័ន្ធ ការវិភាជន៍ថវិកា និងការសម្រេចចិត្តពីគោលនយោបាយពាក់ព័ន្ធ ព្រមទាំងសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត"។

### *V.៧. តម្លាភាព និងសុចរិតភាព*

២៣. តម្លាភាព និងសុចរិតភាព គឺជាគុណតម្លៃស្នូលដែលកម្មវិធីសមាហរណកម្មទាំងអស់គួរដាក់បញ្ចូល។ ជាទូទៅ តម្លាភាពមានន័យថាជាការបើកចំហ ការប្រាស្រ័យទាក់ទង និងគណនេយ្យភាព។ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម គួរចែងឱ្យបានច្បាស់លាស់ដើម្បីឱ្យពលករទេសន្តរប្រវេសក៍ងាយស្រួលយល់ពីគោលនយោបាយ និងនីតិវិធីទាំងនេះ ទាំងនៅក្នុងប្រទេសទទួល និងប្រទេសបញ្ជូន។ ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ និងគ្រួសាររបស់ពួកគេ គួរទទួលបានព័ត៌មានពេញលេញដែលពួកគេត្រូវការ រាប់បញ្ចូលទាំងសេវាកម្ម និងកម្មវិធីដែលមានសម្រាប់ពួកគេផងដែរ។ សុចរិតភាព សំដៅលើការគោរពតាម និងការបន្តគោរពអោយខ្លាំងតាមគោលការណ៍ក្រមសីលធម៌ ដូចជា ភាពស្មោះត្រង់ និងការមិនប្រព្រឹត្តអំពើពុករលួយជាដើម។ ប្រព័ន្ធសុចរិតភាពដែលល្អ ហើយដែលត្រូវបានបញ្ចូលទៅក្នុងកម្មវិធីផ្តល់ការគាំទ្រ អាចទប់ស្កាត់មិនឱ្យមានអំពើពុករលួយ និងការបង្ការការប្រើប្រាស់ធនធានមិនត្រឹមត្រូវ។ កត្តាទាំងនេះ ក៏នាំឱ្យអ្នកគ្រប់គ្រងកម្មវិធីមានគណនេយ្យភាពផងដែរ។

### *V.៨. ភាពជាតំណាងនៃសំឡេងរបស់ពលករទេសន្តរប្រវេសក៍*

២៤. ជាញឹកញាប់ ពលករទេសន្តរប្រវេសក៍ដែល ធ្វើមាតុភូមិនិវត្តន៍ ពុំមានសំឡេងឡើយនៅក្នុងកម្រិតគោលនយោបាយ និងកម្មវិធីដែលរៀបចំសម្រាប់ពួកគេនៅក្នុងប្រទេសបញ្ជូន ដូច្នេះកិច្ចអន្តរាគមន៍ទាំងអស់ គួររៀបចំឡើងដោយផ្អែកលើទស្សនៈ បទពិសោធន៍ និងការយល់ឃើញរបស់ពលករទេសន្តរប្រវេសក៍ ដោយមានការពិគ្រោះយោបល់ និងការចូលរួមពីពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ និងពីសមាជិកសមាគមរបស់ពួកគេ។ ពលករទេសន្តរប្រវេសក៍ដែលត្រឡប់មកវិញគួរមានការលើកទឹកចិត្តឱ្យរួបរួមគ្នាបង្កើតជាសមាគម ដែលចំណុចនេះត្រូវបានចាត់ទុកថាជាអាទិភាពមួយក្នុងប្រការទី២៨ នៃឯកច្ឆន្ទភាពអាស៊ាន ដែលបានចែងថា៖

> "រដ្ឋបញ្ជូនត្រូវធានានូវសិទ្ធិរបស់ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ក្នុងការបង្កើតសមាគម ក៏ដូចជា

ចូលរួមក្នុងការបង្កើតគោលនយោបាយ និងកម្មវិធីនានា ដែលមានឥទ្ធិពលលើពលករទេសន្តរប្រវេសក៍"។

### V.៩. ការចូលរួមរបស់តួអង្គពាក់ព័ន្ធចម្រុះ

២៥. នៅក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីសមាហរណកម្ម កិច្ចសហប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធនានាគួរត្រូវបានលើកទឹកចិត្ត ដើម្បីធានាឱ្យកម្មវិធីទាំងនេះទទួលបានជោគជ័យ ដោយមានការចូលរួមពីសំណាក់រដ្ឋាភិបាលថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន ដៃគូសង្គម អង្គការសង្គមស៊ីវិល ពលករទេសន្តរប្រវេសក៍ ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ សមាគមពលករទេសន្តរប្រវេសក៍ ទីភ្នាក់ងារជ្រើសរើសពលករ ស្ថាប័នឯកជន ព្រមទាំងស្ថាប័នពាក់ព័ន្ធដទៃទៀត និងមន្ត្រីកុងស៊ុល ជាពិសេសអនុព័ន្ធការងារ។ ភាពជាដៃគូរវាងរដ្ឋនិងឯកជន ដូចជា សមាគមជនអន្តោប្រវេសន៍ដែលកំពុងស្នាក់នៅក្រៅប្រទេស អាចជួយឆ្លើយតបបានខ្លះចំពោះបញ្ហា ដែលពាក់ព័ន្ធនឹងកង្វះធនធានសម្រាប់គាំទ្រការធ្វើសមាហរណកម្មនេះ។

### V.១០. គោលការណ៍នៃទំនួលខុសត្រូវរួម រវាងប្រទេសបញ្ជូន និងប្រទេសទទួល

២៦. បុព្វកថានៃឯកច្ឆន្ទភាពអាស៊ាន ចែងថា៖ "ដោយបញ្ជាក់អំពីការចែករំលែក និងតុល្យភាពនៃទំនួលខុសត្រូវរបស់រដ្ឋទទួល និងរដ្ឋបញ្ជូននៃរដ្ឋសមាជិកអាស៊ាន ក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ និងសមាជិកគ្រួសាររបស់ពួកគេនៅក្នុងដំណើរការទេសន្តរប្រវេសន៍ទាំងមូល"។

២៧. ស្ថានទូតនៃរដ្ឋបញ្ជូន ជាពិសេសអនុព័ន្ធការងារ មានតួនាទីសំខាន់ក្នុងការជំរុញឱ្យមានការពិគ្រោះយោបល់ការងារ និងកិច្ចខិតខំប្រឹងប្រែងសហការគ្នា រវាងរដ្ឋបញ្ជូន និងរដ្ឋទទួល។ ប្រការ ១៦ នៃគោលការណ៍ណែនាំអាស៊ានស្តីពីទំនួលខុសត្រូវសង្គមរបស់សហគ្រាសលើកម្លាំងពលកម្ម ក៏ស្នើសុំឱ្យសហគ្រាសទាំងអស់ លើកកម្ពស់សិទ្ធិ និងលក្ខខណ្ឌការងារសមរម្យសម្រាប់ពលករទេសន្តរប្រវេសក៍ផងដែរ។

### *V.១១. ការផ្អែកលើមូលដ្ឋានភស្តុតាង*

២៨. ការផ្អែកលើមូលដ្ឋានភស្តុតាង និងការផ្តល់សេវា សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម គួរធ្វើឡើងផ្អែកលើភស្តុតាងជាក់លាក់ ដែលបានពីការចុះបញ្ជី និងការអង្កេតលើសាវតាររបស់ពលករទេសន្តរប្រវេសក៍ និងពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយបែងចែកតាមអាយុ ភេទ ជំនាញ មុខរបរនៅក្រៅប្រទេស ស្ថានភាពទេសន្តរប្រវេសន៍ស្របច្បាប់ មូលហេតុនៃការធ្វើមាតុភូមិនិវត្តន៍ការត្រៀមលក្ខណៈសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ទីតាំង និងរបាយភូមិសាស្ត្ររបស់ពួកគេ។ល។ សម្រាប់ការប្រមូលទិន្នន័យគ្រប់បែបយ៉ាង ជាការសំខាន់ណាស់ដែលត្រូវគោរព ឯកជនភាពរបស់ពលករ និងត្រូវរក្សាការសម្ងាត់សម្រាប់ទិន្នន័យដែលប្រមូលបាន។

២៩. មូលដ្ឋានភស្តុតាងក៏ជួយដល់ការវាយតម្លៃ ដើម្បីឱ្យមានការយកចិត្តទុកដាក់លើទិដ្ឋភាពផ្សេងៗគ្នានៃសមាហរណកម្ម ដូចជា ទិដ្ឋភាពសេដ្ឋកិច្ច សង្គម ផ្លូវចិត្តសង្គម និងវប្បធម៌ជាដើម។ ខណៈពេលដែលពលករដែលបានធ្វើមាតុភូមិនិវត្តន៍មួយចំនួន ប្រហែលជាត្រូវការការគាំទ្រតែមួយចំនួនដូចជាក្នុងទម្រង់ជាការផ្តល់ព័ត៌មានប៉ុណ្ណោះ តែសម្រាប់ពលករដែលត្រូវបានបង្ខំឱ្យធ្វើមាតុភូមិនិវត្តន៍ ឬធ្វើមាតុភូមិនិវត្តន៍មុនកាលកំណត់ ជនដែលត្រូវបានបណ្តេញចេញ និងជនរងគ្រោះដោយសារការជួញដូរមនុស្ស និងការរំលោភបំពាន អាចមានតម្រូវការសេវាគាំទ្រច្រើនសម្រាប់ឆ្លើយតបទៅនឹងបញ្ហារបស់ពួកគេ។

## VI. គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ប្រកបដោយប្រសិទ្ធភាពរបស់ពលករទេសន្តរប្រវេសក៍

### *VI.១. ក្របខ័ណ្ឌគតិយុត្ត*

#### *VI.១.១. ការរៀបចំ និងការធ្វើអោយប្រសើរឡើងនូវ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាប្រូម និងយន្តការស្ថាប័ន*

៣០. រដ្ឋបញ្ជូននីមួយៗ គួររៀបចំរបាយការណ៍គ្រប់ជ្រុងជ្រោយ ស្តីពីស្ថានភាពនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍ បញ្ហា និងកត្តាប្រឈមនានា គោលនយោបាយ និងការអនុវត្តកម្មវិធីដែលមានស្រាប់ និងចំណុចខ្វះខាត។ របាយការណ៍នេះ ក៏គួររំលេចពីចំណុចខ្វះខាតនៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ និងយន្តការស្ថាប័នផងដែរ។

៣១. បើតាមការពិនិត្យឡើងវិញ រដ្ឋបញ្ជូនគួរចាត់វិធានការកែលម្អក្របខ័ណ្ឌគោលនយោបាយ ព្រមទាំងយន្តការស្ថាប័នរបស់ខ្លួន។ ឯកច្ឆន្ទភាពអាស៊ាន បានអំពាវនាវឱ្យរដ្ឋបញ្ជូន រៀបចំកម្មវិធីសមាហរណកម្មគ្រប់ជ្រុងជ្រោយ សម្រាប់ពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ និងគ្រួសាររបស់ពួកគេ ក៏ដូចជា រៀបចំឱ្យមានជាកម្មវិធីការងារសម្រាប់ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍។ គោលនយោបាយមាតុភូមិនិវត្តន៍ និងសមាហរណកម្មក៏ត្រូវសម្របសម្រួល ប្រទាក់ក្រឡាគ្នាជាមួយនឹងគោលនយោបាយសេដ្ឋកិច្ច គោលនយោបាយស្តីពីការងារនិងមុខរបរ គោលនយោបាយស្តីពីទីផ្សារការងារ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារដែលមានស្រាប់របស់ប្រទេសផងដែរ ដើម្បីធានាឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងគោលនយោបាយទាំងនេះ។ គោលនយោបាយសមាហរណកម្ម ត្រូវតែរៀបចំធ្វើឡើងជាផ្នែកមួយនៃគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងគោលនយោបាយទេសន្តរប្រវេសន៍។

៣២. បុរេលក្ខខណ្ឌដ៏សំខាន់មួយ គឺការបង្កើតយន្តការសម្របសម្រួលទៅដល់ការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ ដើម្បីធានានូវភាពប្រទាក់ក្រឡាគ្នានៃគោលនយោបាយដែលនេះទាមទារ ឱ្យមានការកំណត់អំពីក្រសួង និងស្ថាប័នដែលទទួលបន្ទុកក្នុងការអនុវត្តការងារនេះ។ គេអាចបង្កើតជាក្រុមការងារអន្តរក្រសួង ដោយមានក្រសួង ឬស្ថាប័នឈានមុខណាមួយដើរតួ ជាស្ថាប័នបង្គោល។ គេក៏អាចបង្កើតគណៈកម្មការស្រដៀងគ្នានេះនៅថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានផងដែរ ទៅតាមការចាំបាច់។

៣៣. សម្រាប់ការពិគ្រោះយោបល់ឱ្យបានទូលំទូលាយ រដ្ឋបញ្ជូនគួរបង្កើតយន្តការសម្របសម្រួលដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ ដូចជា តំណាងរដ្ឋាភិបាល ដៃគូសង្គម អង្គការសង្គមស៊ីវិល រួមនឹងសមាគមពលករទេសន្តរ

ប្រវេសក៍ និងអង្គការនៅតាមសហគមន៍ សមាគម និងទីភ្នាក់ងារជ្រើសរើសឯកជន សហគមន៍អ្នកស្រាវជ្រាវ និងបណ្ដាញផ្សព្វផ្សាយនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។ ឈរលើមូលដ្ឋានអាទិភាព គេគួរមានការបង្កើត ឬពង្រឹងយន្តការសម្រាប់ពិគ្រោះយោបល់ បញ្ជូន និងផ្ដល់សេវា ដោយសហការជាមួយនឹងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។

៣៤. រដ្ឋបញ្ជូន និងរដ្ឋទទួល គួរសហការសម្របសម្រួលលើកកម្ពស់លទ្ធភាពទទួលបានយុត្តិធម៌ និងដំណោះស្រាយសម្រាប់ពលករទេសន្តរប្រវេសក៍ នៅតាមបណ្ដោយព្រំដែន ពិនិត្យលើលទ្ធភាពនៃចល័តភាពអត្ថប្រយោជន៍ផ្នែកសន្តិសុខសង្គម ទៅតាមស្ថានភាព និងសម្របសម្រួលការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការមិនទាន់បើកប្រាក់ឈ្នួលអស់ និងបណ្ដឹងទាមទារដទៃទៀត សូម្បីតែក្រោយពេលដែលពលករទេសន្តរប្រវេសក៍បានធ្វើមាតុភូមិនិវត្តន៍ទៅកាន់រដ្ឋបញ្ជូនហើយក៏ដោយ។

៣៥. កិច្ចសហប្រតិបត្តិការបែបនេះ ក៏មានសារៈសំខាន់ និងចាំបាច់សម្រាប់ដោះស្រាយករណីពលករទេសន្តរប្រវេសក៍ដែលពុំមានឯកសារសម្គាល់ខ្លួន ប៉ុន្តែមិនមែនដោយសារតែកំហុសរបស់ពួកគេ ដូចបានលើកឡើងនៅក្នុងប្រការ ៥៦ នៃឯកច្ឆន្ទភាពអាស៊ាន។

៣៦. កិច្ចព្រមព្រៀងទ្វេភាគី និងអនុស្សរណៈស្ដីពីការយោគយល់គ្នានានា គួរបញ្ចូលការប្ដេជ្ញាចិត្ត និងបញ្ញត្តិជាក់លាក់ស្ដីពីការគាំទ្រដល់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មដែលត្រូវផ្ដល់ដោយភាគីទាំងពីរនៃកិច្ចព្រមព្រៀងនេះ ដើម្បីជួយសម្រួលឱ្យមានការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព។

### *VI.១.២. ដំណើរការមាតុភូមិនិវត្តន៍៖ ជំហានសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយប្រសិទ្ធភាព ចេញពីទស្សនៈរដ្ឋបញ្ជូន*

៣៧. រដ្ឋបញ្ជូនគួរសហការជាមួយរដ្ឋទទួល ដើម្បីធានាឱ្យមានការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរ។

៣៨. អនុព័ន្ធការងារ និងស្ថានកុងស៊ុល គួរសហការជាមួយនឹងនិយោជក និង ទីភ្នាក់ងារជ្រើសរើសពលករ និងសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលករ ទេសន្តរប្រវេសក៍ប្រកបដោយសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរនៅក្នុងរដ្ឋទទួល។

៣៩. និយោជក គួរសម្របសម្រួលដល់ដំណើរធ្វើមាតុភូមិនិវត្តន៍របស់ពលករ ទេសន្តរប្រវេសក៍ ក្រោយពេលដែលកិច្ចសន្យាការងាររបស់ពួកគេផុតសុពល-ភាព ដោយស្របតាមខ្លឹមសារនៃកិច្ចសន្យាការងារ ព្រមទាំងច្បាប់ជាតិ និង លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋទទួល។ពលករមិនគួរទទួលទោសដោយសារ តែនិយោជករបស់ពួកគេពុំបានទទួលការអនុញ្ញាត និងការឯកភាពដែល ចាំបាច់នោះឡើយ។

៤០. រដ្ឋបញ្ជូន និងសហគមន៍ គួរស្វាគមន៍ពលករទេសន្តរប្រវេសក៍ដែលបានធ្វើ មាតុភូមិនិវត្តន៍ និងសម្របសម្រួលក្នុងការផ្ដល់សេវាដឹកជញ្ជូនពួកគេ នៅ ពេលពួកគេមកដល់។

៤១. ពលករទេសន្តរប្រវេសក៍ ដែលធ្វើមាតុភូមិនិវត្តន៍ គួរត្រូវបានលើកទឹកចិត្តឱ្យ ចុះឈ្មោះជាមួយអាជ្ញាធរនៅថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន អំពីការធ្វើមាតុ ភូមិនិវត្តន៍របស់ពួកគេ ដើម្បីជួយសម្រួលឱ្យពួកគេបានទទួលសេវាគាំទ្រនានា និងដើម្បីឱ្យពួកគេអាចប្រើប្រាស់ជំនាញ និងធនធានសម្រាប់រួមចំណែក ដល់សហគមន៍ និងសង្គមទាំងមូលទៅតាមការចាំបាច់។

### *VI.១.៣. ព័ត៌មាន និងប្រព័ន្ធទិន្នន័យអំពីពលករ ដែលបានធ្វើមាតុភូមិនិវត្តន៍*

៤២. អ្នកតាក់តែងគោលនយោបាយនៅក្នុងរដ្ឋបញ្ជូន និងរដ្ឋទទួល គួរសហការ គ្នា ដើម្បី កែលម្អការប្រមូល ចងក្រង និងការវិភាគទិន្នន័យពលករទេសន្តរ-ប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយបែងចែកតាមអាយុ និងភេទ និង ធ្វើការចែករំលែកព័ត៌មានទាំងនេះដល់ស្ថាប័នពាក់ព័ន្ធទៅតាមការចាំបាច់។ សម្រាប់ការគ្រប់គ្រងការប្រមូលទិន្នន័យទាំងអស់ ជាការសំខាន់ណាស់ដែល ត្រូវគោរពឯកជនភាពរបស់ពលករ និងរក្សាការសម្ងាត់នៃទិន្នន័យដែលបាន ប្រមូល។

៤៣. រដ្ឋបញ្ជូនគួរផ្ដល់អាទិភាពដល់ការរៀបចំបង្កើត ឬពង្រឹងមជ្ឈមណ្ឌលគ្រប់គ្រង ព័ត៌មាន/ប្រព័ន្ធទិន្នន័យពលករទេសន្តរប្រវេសក៍ដែលមានស្រាប់ និងបានធ្វើ

មាតុភូមិនិវត្តន៍ តាមរយៈការចុះឈ្មោះពួកគេ ដោយសហការជាមួយនឹងក្រសួង/ស្ថាប័នពាក់ព័ន្ធដទៃទៀត ការិយាល័យស្ថិតិជាតិ ស្ថានកុងស៊ុលទីភ្នាក់ងារជ្រើសរើសពលករ និយោជក សហជីព សង្គមស៊ីវិល និងរដ្ឋទទួលដែលមានកាតព្វកិច្ចចាំបាច់។ មជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មាន/ប្រព័ន្ធទិន្នន័យនេះ គួរបញ្ចូលជំនាញថ្មីៗដែលពលករទេសន្តរប្រវេសក៍ទទួលបាននៅក្នុងប្រទេសទទួល ដែលព័ត៌មាននេះអាចចែករំលែកជាមួយនឹងស្ថាប័នរដ្ឋាភិបាលដទៃទៀត ឬក្រុមហ៊ុនឯកជន ដែលអាចផ្តល់ការងារឱ្យពលករទាំងនេះនៅក្នុងប្រទេសបញ្ជូន ទន្ទឹមគ្នានេះ ក៏ត្រូវគោរពឯកជនភាពរបស់ពួកគេផងដែរ។ គួរមានការបង្កើតយន្តការសម្រាប់ពិនិត្យតាមដានលើការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសក៍រួមគ្នា ជាមួយអាជ្ញាធរអន្តោប្រវេសន៍ និងមានការគាំទ្រពីការិយាល័យស្ថិតិជាតិ។

៤៤. រដ្ឋជាសមាជិកអាស៊ានអាចស្វែងរកការគាំទ្រពី អង្គការ ILO ដើម្បីកែលម្អ និងពង្រីកប្រព័ន្ធទិន្នន័យទេសន្តរប្រវេសន៍ការងាររបស់អាស៊ាន ដើម្បីបញ្ចូលព័ត៌មានពីពលករទេសន្តរប្រវេសក៍ ដែលធ្វើមាតុភូមិនិវត្តន៍ ពោលគឺថាតើមានចំនួនថ្មីប៉ុន្មាននាក់ និងពលករដែលបានធ្វើមាតុភូមិនិវត្តន៍រួចទៅហើយប៉ុន្មាននាក់ ក្នុងគោលបំណងដើម្បីឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយសហការជាមួយនឹងរដ្ឋបញ្ជូនផង និងរដ្ឋទទួលផង។

៤៥. រដ្ឋបញ្ជូន គួរពិចារណាបំពេញបន្ថែមប្រព័ន្ធទិន្នន័យបែបបរិមាណវិស័យរបស់ខ្លួន ជាមួយនឹងការអង្កេតតាមកាលកំណត់ដោយប្រើប្រាស់សំណាក ដើម្បីប្រមូលទិន្នន័យបែបគុណវិស័យ ដែលមានប្រយោជន៍អំពីសាវតារ ជំនាញ និងសមត្ថភាព បទពិសោធន៍ និងការយល់ឃើញរបស់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ ដើម្បីរៀបចំសេវា និងការគាំទ្រឱ្យស្របនឹងតម្រូវការរបស់ពួកគេក៏ដូចជា ដើម្បីពិនិត្យតាមដានផលប៉ះពាល់របស់ពួកគេ។ ទាំងរដ្ឋទទួល និងរដ្ឋបញ្ជូន អាចពិចារណាបញ្ចូលគំរូនៃការអនុវត្តស្តីពីទេសន្តរប្រវេសន៍ការងារទៅក្នុងការអង្កេតកម្លាំងពលកម្ម ដែលធ្វើជាទៀងទាត់ យ៉ាងហោចណាស់តាមកាលកំណត់ ដើម្បីបង្កើតនូវព័ត៌មានសាវតា ដែលមានប្រយោជន៍អំពីពលករទេសន្តរប្រវេសក៍ និងពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍។ អង្គការ ILO អាចផ្តល់ជាជំនាញឯកទេស និងការគាំទ្ររបស់ខ្លួនសម្រាប់ការងារនេះ។

៤៦. គួរមានការលើកទឹកចិត្តឱ្យទីភ្នាក់ងារជ្រើសរើសឯកជន រក្សាទុកជាប្រចាំនូវកំណត់ត្រារបស់ពលករទេសន្តរប្រវេសក៍ ដែលទីភ្នាក់ងារជ្រើសរើសឯកជនទាំងនេះបានបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ព្រមទាំងពិនិត្យតាមដាន និងរាយការណ៍ពីការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ពលករទាំងនេះ ជូនស្ថានទូតរបស់រដ្ឋបញ្ជូន និងរដ្ឋាភិបាលនៃរដ្ឋបញ្ជូន។ រដ្ឋាភិបាលនៃរដ្ឋបញ្ជូនគួរតែពិនិត្យជាទៀងទាត់លើការបំពេញតួនាទីរបស់ទីភ្នាក់ងារជ្រើសរើសពលករ ពាក់ព័ន្ធនឹងចំណុចនេះ និងជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសពលករ ផ្អែកតាមវិធានការដែលអាចអនុវត្តទៅបានស្របតាមគោលនយោបាយរបស់រដ្ឋបញ្ជូននីមួយៗ។

### *VI.១.៤. ការវាយតម្លៃលើតម្រូវការរបស់ពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍*

៤៧. ដោយសារតែពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍មានច្រើនប្រភេទ និងមានតម្រូវការខុសៗគ្នា រដ្ឋបញ្ជូនគួរធ្វើការវាយតម្លៃទៅលើតម្រូវ-ការរបស់ពលករទាំងនេះ ជាពិសេសនៅថ្នាក់មូលដ្ឋាន។ ការវាយតម្លៃនេះគួរតែគ្របដណ្តប់លើតម្រូវការផ្នែកសេដ្ឋកិច្ច ចិត្តសាស្រ្តសង្គម និងសុខភាព។ ការវាយតម្លៃលើតម្រូវការ អាចធ្វើឡើងនៅក្នុងប្រទេសគោលដៅដោយអនុព័ន្ធការងារ មន្រ្តីសុខុមាលភាពសង្គម ស្ថានទូត កុងស៊ុល និងត្រូវបញ្ជូនទៅកាន់ទីភ្នាក់ងារពាក់ព័ន្ធនៃរដ្ឋបញ្ជូន ដើម្បីជួយសម្រួលឱ្យមានការអនុវត្តអន្តរាគមន៍ដែលចាំបាច់។ស្ថាប័នទទួលខុសត្រូវអាចត្រូវបានកំណត់ផ្អែកទៅតាមតម្រូវការជាក់លាក់។ ពលករមួយចំនួនអាចធ្វើមាតុភូមិនិវត្តន៍មកកាន់រដ្ឋបញ្ជូនវិញបាន បន្ទាប់ពីបានឆ្លងកាត់ការពិនិត្យសុខភាពនៅក្នុងរដ្ឋទទួលរួច។ ពលករដែលបានធ្វើមាតុភូមិនិវត្តន៍មួយចំនួន ដែលមានបញ្ហាពិការភាពកាយសម្បទា ឬបញ្ហាផ្លូវចិត្ត ការរងរបួស និងជួបប្រទះបញ្ហាប៉ះទង្គិចផ្លូវចិត្ត ប្រហែលជាត្រូវការការស្តារនីតិសម្បទា និងការថែទាំដំបូងសិន ដែលសេវាទាំងនេះត្រូវផ្តល់ដោយអាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារផ្នែកសេវាសុខាភិបាល និងសុខុមាលភាពសង្គម។ ពលករដែលមានបំណងចង់ធ្វើសមាហរណកម្មផ្នែកសេដ្ឋកិច្ច ប្រហែលជាស្វែងរកឱកាសប្រកបមុខរបរចិញ្ចឹមជីវិត ការបណ្តុះបណ្តាលជំនាញ ឬការបណ្តុះបណ្តាលជំនាញ

ឡើងវិញ ការប្រកបមុខជំនួញដោយខ្លួនឯង ការគាំទ្រ និងការទទួលជំបូន្មានបច្ចេកទេស និងការចូលរួមនៅក្នុងទីផ្សារការងារជាដើម។ ការងារទាំងនេះគឺជាការងារដែលត្រូវធ្វើដោយក្រសួងការងារ និងមុខរបរ។ ពលករទេសន្តរ-ប្រវេសក៏ជាបុរស និងស្ត្រី ដែលបានធ្វើមាតុភូមិនិវត្តន៍មកវិញ ក៏មានតម្រូវការ និងផែនការអាជីពខុសៗគ្នាផងដែរ។

### *VI.២. សមាហរណកម្មសេដ្ឋកិច្ច*

៤៨. ស្របតាមប្រការ ២៦ នៃឯកច្ឆន្ទភាពអាស៊ាន រដ្ឋបញ្ជូនត្រូវអភិវឌ្ឍកម្មវិធីសមាហរណកម្មឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់ពលករទេសន្តរប្រវេសក៍ និងគ្រួសាររបស់ពួកគេដែលបានធ្វើមាតុភូមិនិវត្តន៍ ក៏ដូចជា កម្មវិធីផ្ដល់ការងារឱ្យធ្វើដោយគិតពីជំនាញ និងបទពិសោធន៍ដែលពួកគេទទួលបានពីក្រៅប្រទេស និងស្របតាមការអនុវត្តល្អនៅក្នុងតំបន់អាស៊ាន និងតំបន់ដទៃទៀត។ កម្មវិធីនេះត្រូវរៀបចំឡើងក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍ជាតិ (ប្រសិនបើមាន) ក៏ដូចជា យុទ្ធសាស្ត្រ និងគោលនយោបាយជាតិស្ដីពីមុខរបរ និងការងារ។

៤៩. សម្រាប់គោលបំណងនេះសេវាការងារសាធារណៈនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវផ្ដួចផ្ដើមវាយតម្លៃលើតម្រូវការការងារនៅក្នុងស្រុក កំណត់ពីវិស័យការងារដែលមានសក្ដានុពល និងកំណើនរបស់សហគ្រាស កំណត់ពីចំណុចខ្វះខាត និងផ្ដល់សេវាប្រឹក្សាការងារ សេវាផ្គូរផ្គងការងារ និងការបញ្ចូលទៅក្នុងទីផ្សារការងារ ផ្អែកតាមជំនាញរបស់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍។ គេអាចអនុវត្តសកម្មភាពជាជំហានៗ ដើម្បីពង្រឹងសមត្ថភាពនៃសេវាផ្ដល់ការងារ ដើម្បីបំពេញតម្រូវការបន្ថែម។ ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន (សហគ្រាស និងឧស្សាហកម្មក្នុងស្រុក) ក៏អាចរួមចំណែកនៅក្នុងផ្នែកនេះផងដែរ ក្នុងទម្រង់ជាការបណ្ដុះបណ្ដាលជំនាញ ការផ្ដល់ថវិកា/ទុនសម្រាប់ចាប់ផ្ដើមអាជីវកម្ម និងផ្ដល់ឱកាសការងារឱ្យធ្វើជាដើម។

៥០. រដ្ឋបញ្ជូនគួររៀបចំផ្ដល់ការងារទទួលស្គាល់ និងលិខិតបញ្ជាក់ជំនាញ ដែលបានទទួលនៅក្រៅប្រទេសក៏ដូចជា ទទួលស្គាល់ និងផ្ដល់លិខិតបញ្ជាក់ការរៀនសូត្រដែលបានទទួលកន្លងមក ដោយប្រើប្រាស់អ្នកផ្ដល់សេវាបណ្ដុះ

បណ្តាលជំនាញសាធារណៈ និងឯកជនដែលត្រូវបានទទួលស្គាល់គុណភាព ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាន។ ការទទួលស្គាល់ការរៀនសូត្រកន្លងមក គឺជាដំណើរការកំណត់ចងក្រងទុកជាឯកសារ វាយតម្លៃ និងផ្តល់លិខិតបញ្ជាក់លទ្ធផលនៃការរៀនសូត្រក្នុងប្រព័ន្ធក្រៅផ្លូវការ និងក្រៅប្រព័ន្ធធៀបនឹងស្តង់ដារដែលប្រើប្រាស់នៅក្នុងការអប់រំ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ដូច្នេះការទទួលស្គាល់ការរៀនសូត្រកន្លងមកផ្តល់ឱកាសឱ្យពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍អាចទទួលបានការទទួលស្គាល់ជំនាញរបស់ពួកគេដោយមិនចាំបាច់ត្រូវឆ្លងកាត់កម្មវិធីអប់រំ និងបណ្តុះបណ្តាលក្នុងប្រព័ន្ធ ដែលអាចជួយសម្រួលឱ្យពួកគេអាចបានចូលទៅក្នុងទីផ្សារការងារ។ រដ្ឋបញ្ជូនអាចសហការជាមួយនឹងរដ្ឋទទួលដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មានអំពីជំនាញរបស់ពលករទេសន្តរប្រវេសក៍។ គេអាចរៀបចំកម្មវិធីបណ្តុះបណ្តាលខ្លីៗសម្រាប់ពលករ ដើម្បីត្រៀមរៀបចំពួកគេសម្រាប់ការវាយតម្លៃជំនាញ និងបង្កើនជំនាញរបស់ពួកគេ។ ព័ត៌មានអំពីកម្មវិធីទាំងនេះ ចាំបាច់ត្រូវផ្តល់លទ្ធភាព និងបង្កភាពងាយស្រួលសម្រាប់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍។

៥១. មិនថាពួកគេមានផែនការស្វែងរកការងារធ្វើដើម្បីទទួលបានប្រាក់ឈ្នួល ឬបង្កើតមុខរបរដោយខ្លួនឯងនោះទេ ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ និងគ្រួសាររបស់ពួកគេ ត្រូវការការបណ្តុះបណ្តាលជាមូលដ្ឋានអំពីចំណេះដឹងហិរញ្ញវត្ថុ សហគ្រិនភាព និងកម្មវិធីប្រកបមុខរបរចិញ្ចឹមជីវិត។ ការបណ្តុះបណ្តាលទាំងនេះអាចរៀបចំ តាមរយៈអង្គការសង្គមស៊ីវិល អង្គការសហគមន៍នៅតាមមូលដ្ឋាន និងវិស័យឯកជន ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនៅក្នុងករណីដែលចាំបាច់។

៥២. គួរមានការផ្សព្វផ្សាយពីឱកាសចូលរួមក្នុងទីផ្សារការងារ ដល់ពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ ហើយមានបំណងស្វែងរកការងារធ្វើឱ្យស្របទៅតាមជំនាញរបស់ពួកគេ។ គេអាចរៀបចំពិព័រណ៍ការងារ ដើម្បីផ្គូផ្គងជំនាញរបស់ពលករទេសន្តរប្រវេសក៍ ទៅនឹងតម្រូវការរបស់សហគ្រាសក្នុងវិស័យឯកជន និងនិយោជក។ អង្គការនិយោជក និងសភាពាណិជ្ជកម្មអាចបំពេញតួនាទីជាអ្នកសម្របសម្រួលដំណើរការនេះបាន។ រដ្ឋបញ្ជូនគួរ

ពិចារណាបង្កើតភាពជាដៃគូជាមួយនឹងក្រុមហ៊ុនឯកជន ដើម្បីជ្រើសរើសពលករទេសន្តរប្រវេសក៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ឱ្យធ្វើការងារនៅក្នុងក្រុមហ៊ុនរបស់ពួកគេ។

៥៣. រដ្ឋបញ្ជូនគួរផ្សព្វផ្សាយពីកម្មវិធីប្រកបមុខរបរចិញ្ចឹមជីវិត និងកម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពសម្រាប់ពលករទេសន្តរប្រវេសក៍ ដែលធ្វើមាតុភូមិនិវត្តន៍ និងគ្រួសាររបស់ពួកគេដែលមានចំណាប់អារម្មណ៍ចង់ចាប់យកជម្រើសបង្កើតមុខរបរដោយខ្លួនឯង។

៥៤. រដ្ឋបញ្ជូនគួរពិចារណាលើកកម្ពស់សហគ្រិនភាពរបស់ពលករទេសន្តរប្រវេសក៍ និងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសដូចខាងក្រោម៖

- ផ្តល់ឱ្យពលករដែលបានធ្វើមាតុភូមិនិវត្តន៍ នូវការបណ្តុះបណ្តាលកម្រិតមូលដ្ឋានអំពីសហគ្រិនភាព ដោយប្រើប្រាស់កម្មវិធី "ចាប់ផ្តើម និងកែលម្អអាជីវកម្មរបស់អ្នក" របស់អង្គការ ILO។ កម្មវិធីទាំងនេះអាចយកមកកែសម្រួលឱ្យស្របតាមស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាន។
- គប្បីមានការសម្របសម្រួលឱ្យអ្នកដែលបានធ្វើមាតុភូមិនិវត្តន៍ អាចប្រើប្រាស់សេវាឥណទាន និងកម្ចីដែលមានស្រាប់ ព្រោះថាគ្រឹះស្ថានហិរញ្ញវត្ថុអាចមានការស្ទាក់ស្ទើរក្នុងការផ្តល់កម្ចីដល់អ្នកដែលពុំមានទ្រព្យសម្បត្តិ ឬដើមទុន។ នេះរួមមាន កម្មវិធីផ្តល់ប្រាក់កម្ចីខ្នាតតូចដោយមានការគាំទ្រពីរដ្ឋាភិបាលនិងការលើកទឹកចិត្តឱ្យមានការផ្តល់ប្រាក់កម្ចីខ្នាតតូចប្រកបដោយការទទួលខុសត្រូវ។ អ្នកដែលបានធ្វើមាតុភូមិនិវត្តន៍ អាចប្រើប្រាស់ប្រាក់សន្សំ និងប្រាក់បញ្ញើរបស់ខ្លួនបន្ថែមលើឥណទានដែលបានទទួលពីគ្រឹះស្ថានទាំងនេះ។
- ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ និងសម្រេចចិត្តបង្កើតអាជីវកម្មដោយខ្លួនឯង គួរទទួលបានការគាំទ្រក្នុងទម្រង់ជាសម្ភារៈ/កញ្ចប់សម្រាប់ចាប់ផ្តើមអាជីវកម្ម។
- រដ្ឋបញ្ជូន អាចលើកទឹកចិត្តឱ្យមានការបង្កើតសហគមន៍សម្រាប់ដំណើរការអាជីវកម្ម ឬសហគ្រាស ដែលជាការចែករំលែកបទពិសោធន៍ហានិភ័យនិងជួយកៀរគរធនធានបន្ថែមទៀត។វិធីសាស្ត្របែបនេះក៏

អាចមានប្រយោជន៍ជាពិសេសសម្រាប់ក្រុមដែលងាយរងគ្រោះដើម្បីសម្រេចគោលបំណងនៃការធ្វើសមាហរណកម្មរបស់ពួកគេផងដែរ។

- គប្បីបន្តផ្តល់ការគាំទ្រ ដល់ការអភិវឌ្ឍអាជីវកម្មដល់សហគ្រាសរបស់ពលករទេសន្តរប្រវេសក៍ដោយ មានការកៀរគរ ការគាំទ្រផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងនៅនឹងមូលដ្ឋានផ្ទាល់សម្រាប់គោលបំណងនេះ។ កម្មវិធី "ចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់អ្នក និងពង្រីកអាជីវកម្មរបស់អ្នក" របស់អង្គការ ILO គឺជាឧបករណ៍ដ៏មានប្រយោជន៍ក្នុងបរិបទនេះ។

៥៥. រដ្ឋបញ្ជូន គួរពិចារណារៀបចំនូវជម្រើសដែលមានភាពទាក់ទាញសម្រាប់ការវិនិយោគដោយពលករដែលបានធ្វើមាតុភូមិនិវត្តន៍ និងដាក់ចេញនូវគោលនយោបាយបរិយាបន្នហិរញ្ញវត្ថុ។ ដោយសារតែពលករដែលធ្វើមាតុភូមិនិវត្តន៍ទាំងអស់ ប្រហែលជាមិនសុទ្ធតែចាប់អារម្មណ៍ចង់ក្លាយជាសហគ្រិននោះទេ ជាការសំខាន់ណាស់ដែលរដ្ឋបញ្ជូនអាចផ្តល់ឱ្យពួកគេនូវជម្រើសប្រើប្រាស់ប្រាក់សន្សំ និងការវិនិយោគក្នុងទម្រង់ជាផលិតផលហិរញ្ញវត្ថុ ដែលមានភាពទាក់ទាញ ដូចជា ការដាក់ប្រាក់បញ្ញើមានកាលកំណត់ មូលបត្រ និងជម្រើសដទៃទៀត។

### *VI.៣. សមាហរណកម្មសង្គម និងវប្បធម៌*

៥៦. រដ្ឋបញ្ជូន និងតួអង្គពាក់ព័ន្ធដទៃទៀត គួរសម្របសម្រួល និងលើកកម្ពស់សមាហរណកម្មសង្គម និងវប្បធម៌របស់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ទៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូលរបស់ពួកគេ។ ពលករទេសន្តរប្រវេសក៍អាចជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ក្នុងការធ្វើសមាហរណកម្មសង្គមអាស្រ័យទៅតាមរយៈពេលនៃការស្នាក់នៅក្រៅប្រទេស បញ្ហានានាដែលបានឆ្លងកាត់ និងបញ្ហាអសន្តិសុខដែលពួកគេជួបប្រទះ ការរើសអើង ឬការមាក់ងាយជាដើម។ ពលករដែលបានធ្វើមាតុភូមិនិវត្តន៍មួយចំនួន អាចជួបប្រទះនឹងការមាក់ងាយ និងការរើសអើងនៅក្នុងសហគមន៍ និងគ្រួសារផ្ទាល់ខ្លួនរបស់ពួកគេ ដោយសារតែពួកគេខ្លះ បរាជ័យនៅក្នុងការធ្វើទេសន្តរប្រវេសន៍ ការខាតបង់ទ្រព្យសម្បត្តិរបស់គ្រួសារពេលត្រឡប់មកវិញ ដោយសារ

តែជាប់បំណុល ឬត្រូវបានគេបង្ខំឱ្យធ្វើមាតុភូមិនិវត្តន៍ ឬបណ្តេញចេញពីប្រទេសគោលដៅ។ ពលករទេសន្តរប្រវេសក៍ជាស្ត្រី អាចជួបប្រទះនឹងការមាក់ងាយបន្ថែមទៀត នៅពេលដែលការធ្វើទេសន្តរប្រវេសន៍របស់ពួកគេ អាចមានទំនាក់ទំនងជាមួយនឹងការរំលោភបំពានផ្លូវភេទ។ ពលករទេសន្តរប្រវេសក៍ទាំងនេះត្រូវការ ការផ្តល់ប្រឹក្សា និងការគាំទ្រពិសេសផ្នែកផ្លូវចិត្តសង្គម និងអាចផ្តល់តាមរយៈស្ថាប័នរដ្ឋាភិបាល បណ្តាញសង្គម និងសកម្មភាពរបស់អង្គការសង្គមស៊ីវិល ក៏ដូចជាអង្គការសហគមន៍នៅតាមមូលដ្ឋាន។ ពលករដែលបានធ្វើមាតុភូមិនិវត្តន៍អាចបង្កើតជាបណ្តាញក្រុមមិត្តជួយមិត្ត ដើម្បីជួយផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក ក៏ដូចជា ចូលរួមជាមួយនឹងអង្គការសហគមន៍នៅតាមមូលដ្ឋាន ដើម្បីទទួលបានការគាំទ្របន្ថែមទៀត។

៥៧. ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ នាំត្រឡប់មកវិញនូវមូលធនសង្គមក្នុងទម្រង់ជាបណ្តាញទំនាក់ទំនង ក៏ដូចជាគំនិត និងគុណតម្លៃថ្មីៗដែលពួកគេរៀនសូត្របានពីមជ្ឈដ្ឋានក្រៅប្រទេស។រដ្ឋបញ្ជូនគួរមានការលើកទឹកចិត្តឱ្យពួកគេរួមចំណែកដល់សេដ្ឋកិច្ច និងសង្គមនៅក្នុងស្រុក ដោយប្រើប្រាស់មូលធនសង្គមរបស់ពួកគេ។

### *VI.៤. កិច្ចគាំពារសង្គម*

៥៨. ពលករទេសន្តរប្រវេសក៍ និងសមាជិកគ្រួសាររបស់ពួកគេដែលបានធ្វើមាតុភូមិនិវត្តន៍ គួរទទួលបានសេវាគាំពារសង្គម (ដូចជា សេវាថែទាំសុខភាពជាដើម) ដែលត្រូវផ្តល់ឱ្យដោយរដ្ឋបញ្ជូន ស្របតាមប្រព័ន្ធថ្នាក់ជាតិដែលមានស្រាប់។ ពួកគេក៏គួរចូលរួម និង ផ្តល់ការគាំទ្រដល់យន្តការគាំពារសង្គមតាមសហគមន៍នានាដែលមានស្រាប់ផងដែរ។ នៅក្នុងករណីដែលអាចធ្វើទៅបាន គួរស្វែងរកការសហការជាមួយនឹងរដ្ឋទទួល ដើម្បីទទួលបានមកវិញនូវភាគទានរបបសន្តិសុខសង្គម ដែលពលករទេសន្តរប្រវេសក៍បានបង់នៅក្នុងប្រទេសទាំងនោះ ឬជំរុញឱ្យមានចល័តភាពនៃភាគទានរបបសន្តិសុខសង្គម ស្របតាមសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម ព្រមទាំងក្របខ័ណ្ឌ និងផែនការសកម្មភាពថ្នាក់តំបន់ដែលពាក់ព័ន្ធ។

## VII. យុទ្ធសាស្ត្រប្រកបដោយបរិយាប័ន្ន និងការរួមចំណែកដល់ភាពជោគជ័យនៃកម្មវិធីសមាហរណកម្ម

### *VII.១. បរិយាកាសសេដ្ឋកិច្ច នយោបាយ និងសង្គមជារួម*

៥៩. រដ្ឋបញ្ជូនគួរជំរុញកំណើនសេដ្ឋកិច្ច ហើយក្នុងពេលជាមួយគ្នានេះ ត្រូវរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងសង្គមដើម្បីផ្តល់ការលើកទឹកចិត្តឱ្យពលករទេសន្តរប្រវេសក៍ និងអនិកជនធ្វើមាតុភូមិនិវត្តន៍មកវិញ និងចូលរួមនៅក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅក្នុងប្រទេស តាមរយៈការវិនិយោគ និងការផ្ទេរជំនាញ។

### *VII.២. ដំណើរការមុនពេលចេញដំណើរ*

៦០. ដំណាក់កាលមុនពេលចេញដំណើរ ជាដំណាក់កាលដ៏សំខាន់ដែលកំណត់ពីលក្ខខណ្ឌការងារនៅក្រៅប្រទេសសម្រាប់ពលករទេសន្តរប្រវេសក៍ដែលធ្វើការជាបណ្តោះអាសន្ន និងការត្រៀមលក្ខណៈរបស់ពួកគេសម្រាប់ធ្វើមាតុភូមិនិវត្តន៍។ រដ្ឋបញ្ជូន និងភាគីពាក់ព័ន្ធដទៃទៀត គួរធានាឱ្យមានដំណើរការជ្រើសរើសពលករដោយស្មើភាព ចំណាយតិចតួចលើការធ្វើទេសន្តរប្រវេសន៍ និងមិនទទួលរងបន្ទុកបំណុល។

៦១. ការបណ្តុះបណ្តាលតម្រង់ទិសមុនពេលចេញដំណើរ គួរបង្កើនការយល់ដឹងរបស់ពលករអំពីស្ថានភាពផ្នែកច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ទំនៀមទម្លាប់ និងប្រពៃណីរបស់រដ្ឋទទួល ដើម្បីឱ្យពលករទេសន្តរប្រវេសក៍អាចធ្វើការសម្រេចចិត្តត្រឹមត្រូវអំពីការធ្វើការនៅក្រៅប្រទេស។ តាមរយៈការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋទទួល រដ្ឋបញ្ជូនត្រូវរៀបចំកម្មវិធីតម្រង់ទិស និងផ្តល់ការអប់រំឱ្យបានត្រឹមត្រូវមុនពេលចេញដំណើរ។

៦២. ចាំបាច់ត្រូវមានការរៀបចំផ្តល់ព័ត៌មាន ឱ្យបានគ្រប់ជ្រុងជ្រោយមុនពេលចេញដំណើរ ដើម្បីឱ្យពលករទេសន្តរប្រវេសក៍អាចត្រៀមលក្ខណៈ សម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេវិញប្រកបដោយប្រសិទ្ធភាព។ការអប់រំតម្រង់ទិសនេះគួរផ្តោតលើការបង្កើនការយល់ដឹងអំពីប្រព័ន្ធធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ និងមានព័ត៌មានត្រឹមត្រូវសម្រាប់ពលករធ្វើការសម្រេចចិត្ត ចំណេះដឹង

ហិរញ្ញវត្ថុ រួមនឹងរបៀបផ្ញើប្រាក់ និងផែនការសន្សំ ព្រមទាំងបញ្ហាប្រឈម និងឱកាសនានានៅពេលដែលពួកគេធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម ក៏ដូចជាប្រភពព័ត៌មានដែលពាក់ព័ន្ធ។ លើសពីនេះ ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលតម្រង់ទិសមុនពេលចេញដំណើរ គេក៏អាចលើកទឹកចិត្តឱ្យពលកររទេសន្តរប្រវេសក៍រៀបចំផែនការសមាហរណកម្មសម្រាប់ពេលដែលពួកគេត្រូវធ្វើមាតុភូមិនិវត្តន៍មកវិញ ។

### *VII.៣. ក្រោយពេលទៅដល់ និងក្នុងអំឡុងពេលធ្វើការនៅក្រៅប្រទេស*

- ធានាឱ្យមានការត្រៀមលក្ខណៈកាន់តែប្រសើរសម្រាប់ការធ្វើមាតុភូមិនិវត្តន៍

៦៣. រដ្ឋបញ្ជូនគួរសហការជាមួយនឹងរដ្ឋទទួល ក្នុងករណីដែលសមស្រប ដើម្បីធានាឱ្យមានការត្រៀមខ្លួនកាន់តែប្រសើរសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពលកររទេសន្តរប្រវេសក៍ ស្របតាមច្បាប់ការងារជាតិ និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ។

- ព័ត៌មាន និងការប្រឹក្សាដែលត្រូវផ្តល់ឱ្យដោយមន្ត្រីកុងស៊ុល ក្រោយពេលមកដល់

៦៤. មន្ត្រីកុងស៊ុល អាចរៀបចំវគ្គតម្រង់ទិសសម្រាប់ពលករដែលបានមកដល់ប្រទេសគោលដៅ។ ក្នុងករណីដែលអាចធ្វើទៅបាន គួរមានការស្នើសុំការគាំទ្រពីអង្គការនិយោជកនៅក្នុងរដ្ឋទទួល។ កម្មវិធីផ្តល់ការតម្រង់ទិសក្រោយពេលមកដល់ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចពិគ្រោះយោបល់អាប៊ូដាប៊ី (Abu Dhabi Dialogue) អាចយកមកប្រើប្រាស់សម្រាប់ការរៀបចំវគ្គតម្រង់ទិសនេះបាន។ កម្មវិធីទាំងនេះគ្របដណ្តប់លើការផ្តល់ព័ត៌មានសង្ខេបអំពីបរិយាកាសការងារ វប្បធម៌ និងស្ថានភាពរស់នៅ ការយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចក្រោមច្បាប់ស្តីពីការងារ និងកិច្ចសន្យាការងារ និងច្បាប់ដទៃទៀតរបស់ប្រទេសទទួល ការយល់ដឹងផ្នែកហិរញ្ញវត្ថុអំពីការការពារប្រាក់ឈ្នួល ការសន្សំប្រាក់ និងការផ្ញើប្រាក់ត្រឡប់ទៅស្រុកកំណើត ការគ្រប់គ្រងបញ្ហាសុខភាព ការដោះស្រាយវិវាទ និងការទទួលបានយុត្តិធម៌ និងការទទួលបានដំណោះស្រាយក្នុងករណីជួបការលំបាក និងវិបត្តិដែលកើតមានឡើងក្នុងអំឡុងពេលធ្វើការនៅក្នុងរដ្ឋទទួល។

៦៥. មន្ត្រីកុងស៊ុល គួររក្សាទុកកំណត់ត្រារបស់ពលករមកធ្វើការនៅក្នុងប្រទេសទទួល និងផ្តល់ប្រឹក្សាយោបល់ជាមួយពួកគេ ដើម្បីពួកគេអាចត្រៀមរៀបចំខ្លួនកាន់តែប្រសើរសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ នៅពេលដែលចាំបាច់។ ពួកគេក៏គួរផ្សព្វផ្សាយព័ត៌មានអំពីឱកាស និងជម្រើសដែលមានសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ផងដែរ។ ភ្នាក់ងារបង្គោល និងសេវាផ្តល់ការងារឱ្យធ្វើជាសាធារណៈរបស់រដ្ឋបញ្ជូន គួរទំនាក់ទំនងឱ្យបានជិតស្និទ្ធជាមួយនឹងមន្ត្រីកុងស៊ុល ដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធ។

- លើកកម្ពស់សមាហរណកម្មសង្គមរបស់ពលករទេសន្តរប្រវេសក៍

៦៦. មិនថាពួកគេធ្វើការជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ននោះឡើយ ពលករទេសន្តរប្រវេសក៍ ចាំបាច់ត្រូវទទួលបានឱកាសធ្វើសមាហរណកម្មសង្គមជាមូលដ្ឋានក្នុងរដ្ឋទទួល។ ដោយសារតែពលករបណ្តោះអាសន្នភាគច្រើនផ្លាស់ទីដោយពុំមានគ្រួសារទៅជាមួយ វាជាការសំខាន់ណាស់ ដែលពួកគេអាចភ្ជាប់ទំនាក់ទំនងទៅកាន់សមាគមអនិកជនដែលមកពីប្រទេសដូចគ្នា (ជាធម្មតាច្រើនជាពលករជំនាញ)។ គេក៏អាចបង្កើតបណ្តាញមិត្តជួយមិត្តដើម្បីផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមកផងដែរ។ សហជីព និងអង្គការសង្គមស៊ីវិលអាចផ្តល់ការគាំទ្រដល់ពលករទេសន្តរប្រវេសក៍ ដើម្បីឱ្យពួកគេអាចទទួលបានការការពារ និងធ្វើសមាហរណកម្មបានកាន់តែប្រសើរ។ ក្នុងន័យនេះ មន្ត្រីកុងស៊ុលមានតួនាទីសំខាន់។ ក្នុងករណីដែលរដ្ឋទទួលផ្តល់លទ្ធភាពឱ្យមានការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ចូលក្នុងប្រទេសរបស់ពួកគេ គេចាំបាច់ត្រូវមានការកំណត់ និងបញ្ចូលការគាំទ្រ និងការសម្របសម្រួលដែលចាំបាច់ទៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី និង/ឬអនុស្សរណៈស្តីពីការយោគយល់គ្នានាពេលបច្ចុប្បន្ន។

- ការរៀបចំផ្តល់ការទទួលស្គាល់ និងលិខិតបញ្ជាក់ជំនាញ និងការបណ្តុះបណ្តាលជំនាញដែលពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍

៦៧. ពលករទេសន្តរប្រវេសក៍ភាគច្រើនបានទទួលជំនាញ នៅពេលដែលពួកគេធ្វើការក្នុងរដ្ឋទទួល។ ជាការអនុវត្តល្អ និយោជក និងស្ថាប័នដទៃទៀត មិនថារដ្ឋ ឬឯកជននោះឡើយ អាចសិក្សាពីជម្រើសផ្តល់ការបញ្ជាក់ ឬលិខិតបញ្ជាក់ពីជំនាញ រួមមាននឹងប្រវត្តិការងារ បទពិសោធន៍ដែលទទួលបាន និងជំនាញ

ភាសាទៅដល់ពលករ បន្ទាប់ពីពួកគេបានបញ្ចប់កិច្ចសន្យាការងារ ដោយអនុវត្តក្នុងទម្រង់សាកល្បងស្ម័គ្រចិត្ត។ មន្ត្រីកុងស៊ុលអាចសហការជាមួយនឹងនិយោជក និងសមភាគីរបស់ពួកគេនៅក្នុងរដ្ឋទទួលដើម្បីជំរុញឱ្យមានការអនុវត្តបែបនេះ។

៦៨. រដ្ឋទទួលគួរពិចារណាជំរុញឱ្យនិយោជក អង្គការសង្គមស៊ីវិល និងសេវាកុងស៊ុលផ្តល់ការបណ្តុះបណ្តាលជំនាញ ពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍។ ការអនុវត្តល្អដែលសង្កេតឃើញពាក់ព័ន្ធនឹងបរិបទនេះ គឺកម្មវិធីមាតុភូមិនិវត្តន៍ដោយរីករាយនៃសាធារណរដ្ឋកូរ៉េ ដែលក្នុងនោះពលករដែលត្រូវធ្វើមាតុភូមិនិវត្តន៍បានទទួលការបណ្តុះបណ្តាលជំនាញបន្ថែម ដែលមិនពាក់ព័ន្ធនឹងការងាររបស់ពួកគេឡើយ ដោយរដ្ឋាភិបាលជាអ្នករ៉ាប់រងចំណាយសម្រាប់ការបណ្តុះបណ្តាលនេះ។ អង្គការក្រៅរដ្ឋាភិបាលក៏អាចផ្តល់ការបណ្តុះបណ្តាល និងលិខិតបញ្ជាក់ដែលពាក់ព័ន្ធដល់ពលករដែលត្រូវធ្វើមាតុភូមិនិវត្តន៍ផងដែរ ដើម្បីជួយសម្រួលដល់សមាហរណកម្មរបស់ពួកគេនៅក្នុងប្រទេសកំណើត។

- ធានាសេវាគាំពារសង្គម និងចល័តភាពនៃអត្ថប្រយោជន៍សន្តិសុខសង្គម

៦៩. ទាំងរដ្ឋទទួល និងរដ្ឋបញ្ជូនគួរផ្តល់អាទិភាពដល់ការបង្កើនការគ្របដណ្តប់នៃសេវាគាំពារសង្គម។ គួរគោរព និងអនុវត្តតាមការប្តេជ្ញាចិត្តនៅក្នុងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការពង្រឹងសេវាគាំពារសង្គម ព្រមទាំងក្របខ័ណ្ឌ និងផែនការសកម្មភាពតំបន់ដែលពាក់ព័ន្ធ។ គម្រោង និងសកម្មភាពដែលត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាព (២០១៨-២០២៥) សម្រាប់អនុវត្តឯកច្ឆន្ទភាពអាស៊ាន ដើម្បីជំរុញឱ្យមានការផ្តល់សេវាគាំទ្រសង្គមដល់ពលករទេសន្តរប្រវេសក៍ គួរត្រូវបានអនុវត្តជាអាទិភាព។

- ព័ត៌មានអំពីដំណើរការធ្វើមាតុភូមិនិវត្តន៍ ព្រមទាំងកម្មវិធី និងឱកាសសមាហរណកម្ម

៧០. ភ្នាក់ងារបង្គោលនៅក្នុងរដ្ឋបញ្ជូន និងសេវាកុងស៊ុលក្នុងរដ្ឋទទួល គួរសម្របសម្រួលជាមួយគ្នា និងជាមួយភាគីពាក់ព័ន្ធដទៃទៀត ដើម្បីផ្តល់ព័ត៌មានអំពីដំណើរការធ្វើមាតុភូមិនិវត្តន៍ និងឱកាសសមាហរណកម្មទៅដល់ពលករ

ទេសន្តរប្រវេសន៍ ដែលចេញទៅក្រៅប្រទេស និងពលករដែលអាចធ្វើមាតុភូមិនិវត្តន៍មកវិញ។

- ការសម្របសម្រួលដោះស្រាយប្រាក់ឈ្នួលដែលនៅសេសសល់ និងបណ្តឹងដទៃទៀតរបស់ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍

៧១. ការដោះស្រាយបញ្ហាប្រាក់ឈ្នួលដែលនៅសេសសល់ និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់ពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានលើកឡើងនៅក្នុងប្រការ ៤៣ នៃឯកច្ឆន្ទភាពអាស៊ាន៖

> "រដ្ឋទទួលត្រូវការពារសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ ក្នុងអំឡុងពេលធ្វើមាតុភូមិនិវត្តន៍ ដោយរួមបញ្ចូលទាំងការធានាឱ្យបាននូវការគោរពតាមដំណើរការដែលអាចអនុវត្តបាន/ដែលពាក់ព័ន្ធនានានៃការធ្វើមាតុភូមិនិវត្តន៍របស់រដ្ឋទទួល នៅពេលបញ្ចប់កិច្ចសន្យាការងារ/ប័ណ្ណការងារ"។

ដូច្នេះ ពលករដែលនឹងធ្វើមាតុភូមិនិវត្តន៍ និងពលករដែលបានធ្វើមាតុភូមិនិវត្តន៍គួរតែអាចទទួលបានប្រាក់ឈ្នួលដែលនៅសេសសល់របស់ពួកគេមកវិញ និងដោះស្រាយអត្ថប្រយោជន៍ផ្សេងៗទៀតក្នុងអំឡុងពេល ឬក្រោយពេលនៃការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ។

## VIII. ការកសាងសមត្ថភាពដល់ស្ថាប័ន និងដៃគូអនុវត្ត

៧២. ដោយសារតែកម្មវិធីសមាហរណកម្ម មិនមែនជាកម្មវិធីដែលអនុវត្តទូទៅនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ការកសាងសមត្ថភាពភាគីពាក់ព័ន្ធ ជាកិច្ចការសំខាន់មួយ ដើម្បីអាចផ្តល់សេវា និងធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីទាំងនេះ។ អ្នកដែលមានអាទិភាពទទួលបានការបណ្តុះបណ្តាលនៅក្នុងបរិបទនេះ រួមមានមន្ត្រីរដ្ឋាភិបាល នៃរដ្ឋបញ្ជូនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមនឹងមន្ត្រីដែលផ្តល់សេវាការងារសហគមន៍ពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ដៃគូសង្គម សមាគមវិស័យឯកជន និងអង្គការសង្គមស៊ីវិល។ ខណៈពេលដែលអង្គការសង្គមស៊ីវិល និងអង្គការតាមសហគមន៍អនុវត្តកម្មវិធីនៅមានកម្រិតសម្រាប់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ ការងាររបស់អង្គការទាំងនេះនៅបែកខ្ញែកពីគ្នា និងអនុវត្ត

ក្នុងទ្រង់ទ្រាយតូច ដោយសារតែកង្វះសមត្ថភាព និងធនធាន។ គួរមានការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលដោយផ្តោតលើផ្នែកផ្សេងៗ ដែលពាក់ព័ន្ធការផ្តល់ជំនួយសម្រាប់ការធ្វើសមាហរណកម្ម ដូចជា ជំនួយផ្លូវចិត្តសង្គម ការផ្តល់ប្រឹក្សាអំពីការប៉ះទង្គិចផ្លូវចិត្ត កម្មវិធីប្រកបរបរចិញ្ចឹមជីវិត និងការបណ្តុះបណ្តាលពីសហគ្រិនភាព។ ដោយសារតែធនធានមានកំណត់ គួរមានការផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលគ្រូបង្គោលដែលអាចបន្តការបណ្តុះបណ្តាលដល់អ្នកដទៃទៀត។ ការគោរពសិទ្ធិមនុស្ស និងសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប ជាពិសេសបញ្ហារបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី គួរតែដាក់បញ្ចូលទៅជាផ្នែកមួយនៃកម្មវិធីកសាងសមត្ថភាព។

៧៣. គួរមានការស្វែងរកជំនួយពីភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងស្រុក និងដៃគូអភិវឌ្ឍន៍អន្តរជាតិសម្រាប់កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព។ បណ្តាញទេសន្តរប្រវេសន៍នៃអង្គការសហប្រជាជាតិសម្រាប់ផ្តល់ការគាំទ្រដល់ការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) មានយន្តការកសាងសមត្ថភាពមួយសម្រាប់ជួយប្រទេសនានាក្នុងការសម្រេចនូវគោលដៅទេសន្តរប្រវេសន៍ GCM ដែលក្នុងនោះក៏មានបញ្ចូលកម្មវិធីសមាហរណកម្មផងដែរ។ រដ្ឋជាសមាជិកអាស៊ានអាចស្វែងយល់បន្ថែមទៀតពីយន្តការនេះ។

## IX. ការកៀរគរធនធានសម្រាប់សមាហរណកម្ម

៧៤. រដ្ឋបញ្ជូនគួរមានទំនួលខុសត្រូវលើការកៀរគរធនធានសម្រាប់អនុវត្តកម្មវិធីសមាហរណកម្ម និងកម្មវិធីផ្តល់ការងារឱ្យធ្វើ ដែលកំពុងអនុវត្ត ឬដែលគ្រោងនឹងអនុវត្តតាមរយៈការកសាងភាពជាដៃគូជាមួយនឹងភាគីពាក់ព័ន្ធនានា។

៧៥. រដ្ឋបញ្ជូនភាគច្រើនបង្កើតឱ្យមានមូលនិធិលើកកម្ពស់សុខុមាលភាពពលករទេសន្តរប្រវេសន៍ តាមរយៈការប្រមូលថ្លៃសេវាចុះឈ្មោះពីពលករទេសន្តរ-ប្រវេសន៍ ដែលធ្វើដំណើរចេញពីប្រទេសរបស់ខ្លួន។ មូលនិធិដែលប្រមូលបាន អាចយកមកប្រើប្រាស់ប្រកបដោយតម្លាភាព និងយុត្តិធម៌ សម្រាប់គាំទ្រ

មួយផ្នែកដល់ កម្មវិធីមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយចីរភាព ដើម្បីលើកកម្ពស់សុខុមាលភាពពលករទេសន្តរប្រវេសន៍គ្រប់រូប។

៧៦. ជាធម្មតា ពលករទេសន្តរប្រវេសន៍ផ្ញើប្រាក់មកឱ្យគ្រួសារ និងសហគមន៍របស់ពួកគេវិញទុកត្រៀមសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ។ ទាំងនេះគឺជាមូលនិធិផ្ទាល់ខ្លួនរបស់ពលករទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ ហើយវាអាស្រ័យលើថាតើពួកគេសម្រេចចិត្តយ៉ាងណា ដើម្បីរួមភាគទានក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍។ ទាំងរដ្ឋទទួលនិងរដ្ឋបញ្ជូនគួរសហការជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា ធនាគារ និងស្ថាប័នផ្ទេរប្រាក់ ដើម្បីវាយតម្លៃលើលទ្ធភាពកាត់បន្ថយថ្លៃសេវានៃប្រតិបត្តិការផ្ញើប្រាក់ និងផ្តល់ព័ត៌មានឱ្យបានទូលំទូលាយដល់ពលករទេសន្តរប្រវេសន៍ពីវិធីសាស្ត្រផ្លូវការ ដែលចំណាយថ្លៃសេវាតិច សម្រាប់ប្រាក់បញ្ញើរបស់ពួកគេ។ ទន្ទឹមនឹងនេះ កម្មវិធីបង្កើនការយល់ដឹងអំពីហិរញ្ញវត្ថុដល់ពលករទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ នឹងជួយធានាយ៉ាងណាឱ្យពួកគេអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវអំពីរបៀបចំណាយប្រាក់ដែលពួកគេផ្ញើមកនេះ។

៧៧. គួរមានការលើកទឹកចិត្តឱ្យមានការកសាងភាពជាដៃគូរវាងរដ្ឋនិងឯកជននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ភ្នាក់ងាររដ្ឋាភិបាល គ្រឹះស្ថានហិរញ្ញវត្ថុនិយោជក សហគ្រាសឯកជន សភាពាណិជ្ជកម្ម អង្គការសង្គមស៊ីវិល អង្គការសហគមន៍តាមមូលដ្ឋាន និងពលករទេសន្តរប្រវេសន៍ អាចសហការគ្នាក្នុងការអនុវត្តកម្មវិធីសមាហរណកម្ម។ កិច្ចការនេះក៏ត្រូវឱ្យមានការចូលរួមពីសហគមន៍អនិកជននៅក្រៅប្រទេសផងដែរ។

៧៨. កិច្ចខិតខំប្រឹងប្រែងសមាហរណកម្ម គួរទទួលបានការយកចិត្តទុកដាក់ពីអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ បណ្តាញទេសន្តរប្រវេសន៍ នៃអង្គការសហប្រជាជាតិ ដៃគូសន្ទនារបស់អាស៊ាន ដើម្បីអាចទទួលបានការគាំទ្រនានាដែលស្ថាប័នទាំងអស់នេះអាចរៀបចំឱ្យបានក្នុងទម្រង់ដែលជាការផ្តល់ជំនួយបច្ចេកទេស ឬហិរញ្ញវត្ថុជាដើម។ ការធ្វើសមាហរណកម្មមិនគួរធ្វើដាច់ដោយឡែកពីកម្មវិធីផ្សេងទៀតនោះឡើយ ប៉ុន្តែត្រូវបញ្ចូលវាជាផ្នែកមួយនៃកម្មវិធីផ្តល់ជំនួយអភិវឌ្ឍន៍រយៈពេលវែង ដល់រដ្ឋបញ្ជូន ដែលជាលទ្ធផល អាចរួមចំណែកដល់ការធ្វើទេសន្តរប្រវេសន៍ដោយជំរើស។

៧៩. កតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) បានចាប់បង្កើតនូវមូលនិធិមួយសម្រាប់ទេសន្តរប្រវេសន៍ (ដែលហៅថា មូលនិធិ Migration Multi-Partner Trust Fund)។ គេរំពឹងថា មូលនិធិនេះនឹងអាចផ្តល់ថវិកាសម្រាប់រៀបចំគម្រោង និងបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីជំរុញឱ្យមានការរៀបចំគោលនយោបាយទេសន្តរប្រវេសន៍ ដែលមានការគ្រប់គ្រងបានត្រឹមត្រូវ។ រដ្ឋជាសមាជិកអាស៊ានអាចស្វែងយល់ថាតើពួកគេអាចប្រើប្រាស់មូលនិធិនេះសម្រាប់កិច្ចខិតខំប្រឹងប្រែងសមាហរណកម្មរបស់ពួកគេដែរឬទេ។

## X. ការអនុវត្ត និងការត្រួតពិនិត្យតាមដាន និង វាយតម្លៃគោលការណ៍ណែនាំអាស៊ាន

៨០. គួរមានការផ្សព្វផ្សាយគោលការណ៍ណែនាំនេះឱ្យបានទូលំទូលាយដល់អ្នកប្រើប្រាស់គោលដៅ អ្នកពាក់ព័ន្ធនានា និងសាធារណជនជាទូទៅ។ ការផ្សព្វផ្សាយគួរធ្វើឡើង តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា សេចក្តីប្រកាសព័ត៌មាន ទូរទស្សន៍ វិទ្យុ និងបណ្តាញទំនាក់ទំនងសង្គម នៅពេលប្រកាសដាក់ឱ្យអនុវត្តគោលការណ៍ណែនាំនេះ។រដ្ឋជាសមាជិកអាស៊ានត្រូវបានលើកទឹកចិត្តឱ្យបកប្រែគោលការណ៍ណែនាំនេះជាភាសាជាតិ សម្រាប់ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ។

៨១. ការប្រើប្រាស់គោលការណ៍ណែនាំនេះ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត។ ប៉ុន្តែរដ្ឋជាសមាជិកអាស៊ានត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់គោលការណ៍ណែនាំនេះ ឱ្យបានទូលំទូលាយ ក្នុងការធ្វើយ៉ាងណាឱ្យកម្មវិធីមាតុភូមិនិវត្តន៍ និងសមាហរណកម្មនៅក្នុងប្រទេសរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព គ្រប់ជ្រុងជ្រោយ និងប្រកបដោយចីរភាព។ នៅក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះ រដ្ឋជាសមាជិកអាស៊ានត្រូវបានលើកទឹកចិត្តឱ្យសម្របសម្រួល និងសហការជាមួយនឹងភាគីពាក់ព័ន្ធនានា ដូចជា ភ្នាក់ងារពាក់ព័ន្ធនៃរដ្ឋបញ្ជូន និងរដ្ឋទទួលអនុព័ន្ធការងារ សមាគមពលករទេសន្តរប្រវេសក៍ អង្គការសង្គមស៊ីវិល អង្គការនិយោជក អង្គការនិយោជិត និងភាគីពាក់ព័ន្ធដទៃទៀត។

៨២. ការអនុវត្តគោលការណ៍ណែនាំនេះ គួរធ្វើឡើងដោយមានការសម្របសម្រួលជាមួយនឹងការអនុវត្តផែនការយុទ្ធសាស្ត្រទេសន្តរប្រវេសន៍ និងមុខរបរជារួមរបស់រដ្ឋជាសមាជិក ការប្តេជ្ញាចិត្តថ្នាក់តំបន់ដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងឯកសារឯកច្ឆន្ទភាពអាស៊ាន និងការប្តេជ្ញាចិត្តអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត ដូចជា របៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ គោលដៅអភិវឌ្ឍន៍ដោយចីរភាព និង GCM ជាដើម។

៨៣. ការតាមដាន ពិនិត្យតាមកាលកំណត់ និងវាយតម្លៃលើស្ថានភាពនៃការអនុវត្តគោលការណ៍ណែនាំនេះ គួរធ្វើឡើងដោយដៃគូត្រីភាគី និងភ្នាក់ងារពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមានការគោរពតាមគោលការណ៍ណែនាំនេះ ក្នុងគោលនយោបាយជាតិ និងគោលនយោបាយរបស់អាស៊ាន។ លេខាធិការដ្ឋានអាស៊ានអាចផ្តល់ការគាំទ្រ និងដំបូន្មានអំពីដំណើរការពិនិត្យតាមដាន និងវាយតម្លៃនេះ។

# ឧបសម្ព័ន្ធទី ១៖ សន្ទានុក្រម វាក្យស័ព្ទគន្លឹះ អមនឹងនិយមន័យ

## ១. អាស៊ាន

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលមានរដ្ឋជាសមាជិកចំនួន១០ គឺ៖ ព្រុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

## ២. រដ្ឋទទួល

រដ្ឋសមាជិកអាស៊ាន ដែលទទួលពលករទេសន្តរប្រវេសក៍។[៤]

វាក្យស័ព្ទដែលគេប្រើប្រាស់ទូទៅ គឺ "ប្រទេសគោលដៅ រដ្ឋគោលដៅ ឬរដ្ឋផ្តល់ការងារ[៥]"។

## ៣. រដ្ឋបញ្ជូន

រដ្ឋសមាជិកអាស៊ាន ដែលពលករទេសន្តរប្រវេសក៍មានសញ្ជាតិរបស់ខ្លួន។[៦]

ពាក្យដែលគេប្រើញឹកញាប់គឺ "ប្រទេសប្រភពដើម រដ្ឋប្រភពដើម ឬប្រទេសកំណើត"។

## ៤. ត្រីភាគីនិយម និងដៃគូត្រីភាគី

ត្រីភាគីនិយម ត្រូវបានអង្គការ ILO ឱ្យនិយមន័យថាជាអន្តរកម្មរវាងរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត (តាមរយៈតំណាងរបស់ពួកគេ) ក្នុងនាមជាដៃគូស្មើភាពគ្នា និងឯករាជ្យ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលជាការបារម្ភរួមគ្នារបស់ពួកគេ។ និយាយម្យ៉ាងទៀត ត្រីភាគីសំដៅលើការចូលរួមនៃអង្គការនិយោជក និងអង្គការនិយោជិត រួមនឹងរដ្ឋាភិបាល

---

៤ ឯកច្ឆ័ន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០១៧ ប្រការ ៦។

៥ អាស៊ាន៖ កម្រងព័ត៌មានអំពីកម្មវិធីអប់រំពលករទេសន្តរប្រវេសក៍ និងកម្មវិធីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព (ហ្សាការតា លេខាធិការអាស៊ាន ឆ្នាំ ២០១៧)។

៦ ឯកច្ឆន្ទអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ឆ្នាំ២០១៧ ប្រការ ៥។

៧ ILO៖ "សទិសន័យរបស់ ILO", https://metadata.ilo.org/thesaurus.html.

ក្នុងការសម្រេចចិត្តនានា ដោយស្មើភាពគ្នា។ ត្រីភាគីពុំមានន័យថា ភាគីទាំងបីមានការទទួលខុសត្រូវដូចគ្នានោះឡើយ។ ភាគីនីមួយៗមានតួនាទី និងមុខងារច្បាស់លាស់ដែលត្រូវបំពេញ។[៨]

### ៥. អង្គការនិយោជក

អង្គការវិជ្ជាជីវៈនិយោជក ដែលមានតួនាទីលើកកម្ពស់ និងការពារផលប្រយោជន៍របស់និយោជក។[៩]

### ៦. អង្គការនិយោជិត

អង្គការវិជ្ជាជីវៈដែលមានតួនាទីលើកកម្ពស់ និងការពារផលប្រយោជន៍របស់កម្មករនិយោជិត។[១០]

អង្គការនិយោជិត ជាធម្មតា មានវិសាលភាពគ្របដណ្តប់ លើសពីសហគ្រាសមួយ ដោយត្រូវបានបង្កើតឡើងដើម្បីការពារ ឬលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច និងសង្គមនៃសមាជិករបស់ខ្លួន តាមរយៈការធ្វើសកម្មភាពជាសមូហភាព។[១១]

### ៧. អង្គការសង្គមស៊ីវិល

ក្រុមអង្គការក្រៅរដ្ឋាភិបាល ស្ថាប័ន ឬសមាគមសង្គម និងស៊ីវិល ដែលត្រូវបានរៀបចំចងក្រងផ្លូវការ ( តិចក្តី ឬច្រើនក្តី ) និងមានគោលបំណងពង្រឹងការអនុវត្ត ឬផ្លាស់ប្តូរវិធាន បទដ្ឋាន និង/ឬរចនាសម្ព័ន្ធសង្គមនាពេលបច្ចុប្បន្ន។

រាប់បញ្ចូលអង្គការក្រៅរដ្ឋាភិបាល សហជីព ស្ថាប័នសិក្សាស្រាវជ្រាវ ក្រុមប្រជាពលរដ្ឋ សមាគមវិជ្ជាជីវៈ សមាគមស្ម័គ្រចិត្ត។ល។[១២]

---

៨ ILO៖ សង្វាតសង្គមត្រីភាគីថ្នាក់ជាតិ៖ មគ្គុទេសក៍ ILO សម្រាប់លើកកម្ពស់អភិបាលកិច្ច អង្គភាពសង្វាតសង្គម និងត្រីភាគី នាយកដ្ឋានអភិបាលកិច្ច និងត្រីភាគី ( ទីក្រុងហ្សឺណែវ ឆ្នាំ ២០១៣ )។

៩ អនុសញ្ញា ILO ឆ្នាំ ១៩៤៨ ( លេខ ៨៧ ) មាត្រា ១០ សេរីភាពនៃការបង្កើតសមាគម និងការពារសិទ្ធិចងក្រង។

១០ Ibid.

១១ ILO៖ "សទិសន័យរបស់ ILO", https://metadata.ilo.org/thesaurus.html.

១២ Ibid.

## ៨. ពលករទេសន្តរប្រវេសន៍

ឯកច្ឆន្ទភាពអាស៊ានឱ្យនិយមន័យពលករទេសន្តរប្រវេសន៍ ដូចតទៅ៖

ពលករទេសន្តរប្រវេសន៍ សំដៅទៅលើបុគ្គលទាំងឡាយណាដែលនឹងត្រូវចូលរួម ឬនឹងត្រូវជួលឱ្យធ្វើការងារ កំពុងចូលរួម ឬកំពុងត្រូវជួលឱ្យធ្វើការងារ ឬបាននិងកំពុងចូលរួម ឬបាននិងកំពុងត្រូវជួលឱ្យធ្វើការងារ ក្នុងសកម្មភាពដែលទទួលបាននូវប្រាក់កម្រៃនៅក្នុងរដ្ឋដែលមិនមែនជាប្រទេសកំណើតរបស់បុគ្គលនោះ។

និយមន័យនេះស្របគ្នានឹងនិយមន័យរបស់អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ICRMW)៖

ពលករទេសន្តរប្រវេសន៍ គឺជាបុគ្គលទាំងឡាយណាដែលនឹងត្រូវជួល ត្រូវបានជួល ឬបានជួលកន្លងមក ឱ្យធ្វើការងារក្នុងសកម្មភាពដែលទទួលបាននូវប្រាក់កម្រៃនៅក្នុងរដ្ឋដែលមិនមែនជាប្រទេសកំណើតរបស់បុគ្គលនោះ។

## ៩. ពលករទេសន្តរប្រវេសន៍ដែលមានឯកសារត្រឹមត្រូវ និងពលករទេសន្តរប្រវេសន៍ដែលមិនមានឯកសារគ្រប់គ្រាន់

ឯកច្ឆ័ន្ទភាពអាស៊ានឱ្យនិយមន័យពាក្យថា ពលករទេសន្តរប្រវេសន៍ដែលមិនមានឯកសារគ្រប់គ្រាន់ដូចតទៅ៖

ពលករទេសន្តរប្រវេសន៍ដែលមិនមានឯកសារគ្រប់គ្រាន់ គឺសំដៅទៅបុគ្គលដែលមិនបានអនុវត្តតាមលក្ខខណ្ឌ ដែលផ្តល់ឱ្យសម្រាប់គាត់ក្នុងការចូលទៅក្នុងរដ្ឋទទួលដោយស្របច្បាប់ និងស្នាក់នៅដោយស្របច្បាប់ ក្នុងអំឡុងពេលនៃការធ្វើការងារ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនៃរដ្ឋទទួល។ និយមន័យនេះ រួមបញ្ចូលទាំងពលករទេសន្តរប្រវេសន៍ដែលបាននិងកំពុងត្រូវបានជួលឱ្យធ្វើការប៉ុន្តែពួកគេមិនត្រូវបានជួលដោយស្របច្បាប់ទៀតទេ នៅក្នុងសកម្មភាពទទួលបានប្រាក់កម្រៃ។

## ១០. សមាហរណកម្ម

ពុំមាននិយមន័យដែលត្រូវឯកភាពជាសកលជុំវិញទស្សនទានសមាហរណកម្មនោះឡើយ។ វេទិកា ស្តីពីមាតុភូមិនិវត្តន៍នៃពលករទេសន្តរ-

ប្រវេសក៍ និងការអភិវឌ្ឍ (RDP) នៃវិទ្យាស្ថានសាកលវិទ្យាល័យអឺរ៉ុប (ដែលធ្វើការសិក្សាវិភាគលើការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មនៅតាមតំបន់នានា) ឱ្យនិយមន័យសមាហរណកម្មថាជា៖ "ដំណើរការដែលពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ចូលរួមនៅក្នុងជីវភាពសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយនៃប្រទេសកំណើតរបស់ពួកគេ"។ ខុសពីការធ្វើមាតុភូមិនិវត្តន៍ សមាហរណកម្មគឺជាទស្សនទានដែលមានច្រើនផ្នែកដែលគេមិនងាយនឹងវាស់វែងនោះឡើយ។ គេអាចមើលឃើញសមាហរណកម្មនៅច្រើនកម្រិត៖ កម្រិតបុគ្គល គ្រួសារ សហគមន៍ សេដ្ឋកិច្ច និងសង្គម។ សៀវភៅណែនាំ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHCR) លើកឡើងថា ស្ថានភាពចុងក្រោយនៃការធ្វើសមាហរណកម្ម គឺដើម្បីទទួលបានសិទ្ធិនយោបាយ សិទ្ធិស៊ីវិល សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ឱ្យបានពេញលេញជាសកល។[១៣]

## ១១. ការធ្វើទេសន្តរប្រវេសន៍សារជាថ្មី

ពលករទេសន្តរប្រវេសក៍ដែលត្រឡប់ទៅរកប្រទេសប្រភពដើមវិញ អាចសម្រេចចិត្ត**ធ្វើទេសន្តរប្រវេសន៍**ម្តងទៀត មិនយូរប៉ុន្មានក្រោយពេលធ្វើមាតុភូមិនិវត្តន៍ ដោយសារមូលហេតុជាច្រើន ដូចជាស្វែងរកឱកាសកាន់តែប្រសើរ ការមិនទទួលជោគជ័យ ឬមិនចាប់អារម្មណ៍លើសមាហរណកម្ម ឬដើម្បីសងបំណុល តាមរយៈការរកចំណូលនៅក្រៅប្រទេស។ល។

## ១២. ការធ្វើមាតុភូមិនិវត្តន៍

ការធ្វើមាតុភូមិនិវត្តន៍ គឺជាវាក្យស័ព្ទគ្របដណ្តប់រួម ដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនប្រភេទ ប៉ុន្តែជាទូទៅ សំដៅលើការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសក៍ ពីប្រទេសគោលដៅ ត្រឡប់ទៅប្រទេសដើមរបស់ពួកគេវិញ។ កម្រងព័ត៌មានអាស៊ាន ស្តីពីកម្មវិធីអប់រំពលករទេសន្តរប្រវេសក៍ និងទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព បានឱ្យនិយមន័យដូចតទៅ៖ "ការធ្វើមាតុភូមិនិវត្តន៍៖ នៅក្នុងន័យទូទៅ ជាសកម្មភាព ឬដំណើរការវិលត្រឡប់ទៅប្រទេសដើមវិញ។ ការធ្វើមាតុភូមិនិវត្តន៍បែងចែកជាប្រភេទតូចៗ

---

១៣ សៀវភៅណែនាំស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHCR) (ហ្សឺណែវ ឆ្នាំ ២០០៤) ទំព័រទី ៧។

ដែលអាចរៀបរាប់ពីរបៀបដែលការធ្វើមាតុភូមិនិវត្តន៍ត្រូវបានអនុវត្ត ដូចជា ស្ម័គ្រចិត្ត ត្រូវបានបង្ខំ មានការជួយ និងការធ្វើមាតុភូមិនិវត្តន៍ដោយមិនបានព្រៀងទុកជាដើម"។[១៤]

បើតាមផ្នែកស្ថិតិរបស់អង្គការសហប្រជាជាតិ ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍គឺជា "បុគ្គលដែលធ្វើមាតុភូមិនិវត្តន៍មកប្រទេសសញ្ជាតិរបស់ពួកគេ ក្រោយពីបានធ្វើជាពលករទេសន្តរប្រវេសក៍អន្តរជាតិ (មិនថារយៈពេលខ្លី ឬរយៈពេលវែង) នៅក្នុងប្រទេសមួយទៀត ហើយមានបំណងស្នាក់នៅក្នុងប្រទេសរបស់ខ្លួនយ៉ាងហោចណាស់ ១ឆ្នាំ"។[១៥] ខណៈពេលដែលនិយមន័យនេះចាត់ទុកប្រទេសកំណើតថាជាប្រទេសដែលបុគ្គលនោះមានសញ្ជាតិ អ្នកខ្លះលើកឡើងថា យកល្អគួរប្រើប្រទេសកំណើតជាលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ពីពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ ព្រោះថាអ្នកដែលចូលសញ្ជាតិនៅក្នុងប្រទេសគោលដៅអាចត្រូវបានគេផាត់ចេញ។[១៦] ពលករទេសន្តរប្រវេសក៍ ក៏អាចផ្លាស់ទៅប្រទេសទី៣ មួយ ឬច្រើនជាងនេះ មុននឹងត្រឡប់ទៅប្រទេសដើមរបស់ពួកគេវិញ។

គោលការណ៍ណែនាំរបស់អង្គការ ILO ឆ្នាំ២០១៨ ស្តីពីស្ថិតិទេសន្តរ-ប្រវេសន៍អន្តរជាតិលើកឡើងថា "ពលករទេសន្តរប្រវេសក៍អន្តរជាតិ ដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានឱ្យនិយមន័យថា ជានិវាសនជនបច្ចុប្បន្ននៃប្រទេសដែលពួកគេធ្លាប់ធ្វើជាពលករទេសន្តរប្រវេសក៍អន្តរជាតិនៅក្នុងប្រទេសមួយទៀត ឬប្រទេសច្រើនផ្សេងទៀត។ រយៈពេលបំពេញការងារនៅក្រៅប្រទេសជាអប្បបរមា ដើម្បីឱ្យមនុស្សម្នាក់ត្រូវបានគេចាត់ទុកថាជាពលករទេសន្តរ-ប្រវេសក៍អន្តរជាតិដែលធ្វើមាតុភូមិនិវត្តន៍មកវិញ គួរមានរយៈពេលខ្លី ដូចជា ៦ ខែជាដើម"។[១៧]

---

១៤ កម្រងព័ត៌មានអាស៊ានស្តីពីកម្មវិធីអប់រំពលករទេសន្តរប្រវេសក៍ និងទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព (លេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាកាតា ឆ្នាំ ២០១៧)។

១៥ ផ្នែកស្ថិតិរបស់អង្គការសហប្រជាជាតិ៖ អនុសាសន៍ស្តីពីស្ថិតិទេសន្តរប្រវេសន៍អន្តរជាតិ៖ កំណែទី ១,ឯកសារស្ថិតិសេរី M លេខ ៥៨ កំណែទី ១ (ទីក្រុងញូយ៉ក ឆ្នាំ ១៩៩៨) ទំព័រទី ៩៤។

១៦ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)៖ "ការធ្វើមាតុភូមិនិវត្តន៍ ៖ទស្សនៈយល់ឃើញថ្មី" នៅក្នុង OECD៖ ទស្សនវិស័យទេសន្តរប្រវេសន៍អន្តរជាតិ (ទីក្រុងប៉ារីស ឆ្នាំ ២០០៨)។

១៧ ILO៖ គោលការណ៍ណែនាំពាក់ព័ន្ធស្ថិតិទេសន្តរប្រវេសន៍ការងារអន្តរជាតិ, ICLS/20/2018/គោលការណ៍ណែនាំ, សន្និសីទអ្នកជំនាញស្ថិតិការងារអន្តរជាតិលើកទី ២០ ទីក្រុងហ្សឺណែវ ខែតុលា ឆ្នាំ ២០១៨, ទំព័រទី ៨-៩។

## ១៣. ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព

តាមទស្សនៈរបស់រដ្ឋបញ្ជូន ការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយប្រសិទ្ធភាពមានន័យថាពលករទេសន្តរប្រវេសក៍នៃរដ្ឋបញ្ជូនធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ក្រោយពេលបានសម្រេចគោលដៅនៃការធ្វើទេសន្តរប្រវេសន៍របស់ពួកគេទៅក្រៅប្រទេស។

សមាហរណកម្មប្រកបដោយប្រសិទ្ធភាពមានន័យថា ពលករដែលបានធ្វើមាតុភូមិនិវត្តន៍បានធ្វើសមាហរណកម្មប្រកបដោយជោគជ័យត្រឡប់ទៅក្នុងគ្រួសារ សហគមន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេវិញ។ ទាំងនេះក៏មានន័យថា ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ បានសម្រេចនូវសមាហរណកម្មសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងប្រទេសកំណើតរបស់ពួកគេ។

## ១៤. ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍

ពលករទេសន្តរប្រវេសក៍បានមកដល់ប្រទេសកំណើតក្រោយពីបានធ្វើការងារនៅក្រៅប្រទេសរួច។

## ១៥. ពលករទេសន្តរប្រវេសក៍ដែលកំពុងធ្វើមាតុភូមិនិវត្តន៍

ពលករទេសន្តរប្រវេសក៍ដែលកំពុងស្ថិតនៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកំណើតក្រោយពេលធ្វើការងារនៅក្រៅប្រទេស។

## ១៦. ទេសន្តរប្រវេសន៍វិលជុំ

ទេសន្តរប្រវេសន៍វិលជុំ សំដៅលើជនទេសន្តរប្រវេសក៍ដែលផ្លាស់ទីបណ្តោះអាសន្នដដែលៗ (អាចផ្លូវការ ឬមិនផ្លូវការ) ឆ្លងព្រំប្រទល់ជាធម្មតាដើម្បីរកការងារធ្វើ។ បើតាមនិយមន័យ ទេសន្តរប្រវេសន៍វិលជុំទាំងអស់ គឺជាទេសន្តរប្រវេសន៍បណ្តោះអាសន្ន។ ដូច្នេះទេសន្តរប្រវេសន៍វិលជុំមានន័យថាជាការធ្វើទេសន្តរប្រវេសន៍ដដែល ហើយវាត្រូវគ្នានឹងទស្សនទាននៃការធ្វើមាតុភូមិនិវត្តន៍ដែរ ព្រោះមាតុភូមិនិវត្តន៍គឺជាផ្នែកមួយនៃការផ្លាស់ទីវិលជុំ។

## ១៧. សមាហរណកម្មប្រកបដោយចីរភាព

សមាហរណកម្មប្រកបដោយចីរភាពកន្លងមកត្រូវបានគេបកស្រាយថាជាស្ថានភាពដែលពលករទេសន្តរប្រវេសក៍ស្នាក់នៅក្នុងប្រទេសកំណើតក្នុងរយៈពេលវែងមួយ ដោយមិនមានបំណងធ្វើទេសន្តរប្រវេសន៍ជាថ្មី ព្រោះថាពួកគេបានសម្របខ្លួនបានយ៉ាងល្អទៅនឹងសហគមន៍សេដ្ឋកិច្ច និងសង្គមមូលដ្ឋាន។ ប៉ុន្តែ សមាហរណកម្មប្រកបដោយចីរភាព មិនគួរមានន័យថាពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ត្រូវតែបន្តនៅក្នុងប្រទេសកំណើតដោយមិនមានបំណងធ្វើទេសន្តរប្រវេសន៍ឡើងវិញនៅដំណាក់កាលក្រោយទៀតនោះឡើយ។

## ឧបសម្ព័ន្ធទី ២៖ តារាងរៀបរាប់សង្ខេបពីការអនុវត្តល្អមួយចំនួននៅអាស៊ាន និងអន្តរជាតិ

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
| --- | --- | --- | --- |
| **បញ្ញត្តិស្តីពីការធ្វើសមាហរណកម្មត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ គោលការណ៍ណែនាំ** (G)-6.1.1 | ហ្វីលីពីន៖ ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីសមាហរណកម្ម | ច្បាប់ស្តីពីពលករទេសន្តរប្រវេសក៍ និងជនជាតិហ្វីលីពីននៅក្រៅប្រទេស ឆ្នាំ១៩៩៥ ចាត់ទុកការគាំទ្រដល់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ជាផ្នែកនៃអាទិភាពគោលនយោបាយរបស់ប្រទេសហ្វីលីពីន។ ច្បាប់នេះដាក់ចេញនូវសេវាសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ | ក្រសួងការងារ និងមុខរបរនៃរដ្ឋាភិបាលហ្វីលីពីន៖ "សេវាសមាហរណកម្មសម្រាប់ពលករហ្វីលីពីនដែលធ្វើការនៅក្រៅប្រទេស" https://www.dole.gov.ph/reintegration-services-for-overseas-filipino-workers/ |
| | ស្រីលង្កា៖ គោលនយោបាយរង និងផែនការសកម្មភាពជាតិស្តីពីការធ្វើមាតុភូមិនិវត្តន៍ និង | បញ្ញត្តិល្អៗពាក់ព័ន្ធនឹងអភិក្រមគ្រប់ជ្រុងជ្រោយ និងដំណើរការរៀបចំគោលនយោបាយ និងផែនការសកម្មភាព៖ ការស្រាវជ្រាវជាមុនលើពលករដែលធ្វើមាតុភូមិនិវត្តន៍, គំនិតផ្តួចផ្តើមសាកល្បង និងការចងក្រងមេរៀនដែលទទួលបាន និងការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ។ ក្របខ័ណ្ឌ | ក្រសួងការងារក្រៅប្រទេសរដ្ឋាភិបាលស្រីលង្កា។ គោលនយោបាយរង និងផែនការសកម្មភាពជាតិស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍ |

| ប្រភេទនៃការអនុវត្តល្អ | | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | សមាហរណកម្ម របស់ពលករ ទេសន្តរប្រវេសក៍ (NAPPR) ឆ្នាំ២០១៥ | គោលនយោបាយរងនេះគ្របដណ្តប់លើ ៥ ផ្នែក៖<br>១. សមាហរណកម្មសង្គមនៃពលករដែលធ្វើមាតុភូមិនិវត្តន៍<br>២. សមាហរណកម្មសេដ្ឋកិច្ចនៃពលករដែលធ្វើមាតុភូមិនិវត្តន៍<br>៣. សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពលករដែលធ្វើមាតុភូមិនិវត្តន៍ និងសមាជិកគ្រួសាររបស់ពួកគេ<br>៤. ការជំរុញលើកទឹកចិត្ត ផ្នែកស៊ីវិល និងនយោបាយដល់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ និង<br>៥. ការគ្រប់គ្រងដំណើរការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព<br>ទីភ្នាក់ងារអនុវត្តន៍ គឺការិយាល័យការងារក្រៅប្រទេសរបស់ស្រីលង្កា (SLBFE) ដោយបាន | (Colombo, 2015), https://www.ilo.org/ colombo/whatwedo/publications/WCMS_497323/lang--en/index.htm<br>ILO៖ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសក៍ ដោយផ្តោតការយកចិត្តទុកដាក់លើរដ្ឋជាសមាជិកអាស៊ាន, ឯកសារសាវតារ រៀបចំសម្រាប់សិក្ខាសាលាអាស៊ានស្តីពីកម្មវិធីសមាហរណកម្ម សម្រាប់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | | បង្កើតនូវអង្គភាពមួយដាច់ដោយឡែក ដើម្បីទទួលបន្ទុកសមាហរណកម្ម | ទីក្រុងហ្សាការតា ថ្ងៃទី២៧ - ២៨ ខែសីហា (ទីក្រុងបាងកក ឆ្នាំ២០១៩) |
| | ឥណ្ឌូណេស៊ី៖ ច្បាប់លេខ ១៨/២០១៧ របស់សាធារណរដ្ឋឥណ្ឌូណេស៊ី ស្តីពីការការពារពលករ-ទេសន្តរប្រវេសក៍ឥណ្ឌូណេស៊ី | ច្បាប់ចែងថា៖ "រដ្ឋមានកាតព្វកិច្ចកែលម្អប្រព័ន្ធការពារទាំងមូលសម្រាប់ពលករទេសន្តរប្រវេសក៍ឥណ្ឌូណេស៊ី និងគ្រួសាររបស់ពួកគេ ដែលឆ្លុះបញ្ចាំងពីគុណតម្លៃមនុស្សធម៌ និងសេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលធ្វើការងារ"។ មាត្រា ២៤ - ២៨ ចែងពីទម្រង់ផ្សេងៗនៃការការពារក្រោយពីធ្វើការងារ ហើយមាត្រា ៣៩ - ៤២ កំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចាប់ពីថ្នាក់ភូមិរហូតដល់ថ្នាក់ជាតិ ក្នុងការសម្របសម្រួលសមាហរណកម្មសង្គម និងសេដ្ឋកិច្ចដល់ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍។ | |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| **ការបណ្តុះបណ្តាលជំនាញដែលផ្តល់ដល់ពលករទេសន្តរប្រវេសន៍ដែលនឹងធ្វើមាតុភូមិនិវត្តន៍ដោយរដ្ឋទទួល** G-6.2 (កថាខណ្ឌ ៤៧) | សាធារណរដ្ឋកូរ៉េ៖ កម្មវិធីធ្វើមាតុភូមិនិវត្តន៍ដោយរីករាយនៃប្រព័ន្ធអនុញ្ញាតិមុខរបរ (EPS) | កម្មវិធីដែលធ្វើមាតុភូមិនិវត្តន៍ដោយរីករាយត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០០៩ ក្រោមប្រព័ន្ធ EPS ដើម្បីមិនលើកទឹកចិត្តឱ្យពលករក្រោមប្រព័ន្ធនេះ ស្នាក់នៅហួសកាលកំណត់។<br>ចំណុចសំខាន់៖<br>• ទទួលស្គាល់ថាសមាហរណកម្មប្រកបដោយជោគជ័យជាទំនួលខុសត្រូវរួមគ្នា<br>• ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ថែមលើជំនាញដែលមានស្រាប់របស់ពលករ និង<br>• គាំទ្រពលករដែលធ្វើមាតុភូមិនិវត្តន៍ក្នុងការរកការងារធ្វើ តាមរយៈការផ្គូរផ្គងការងារ និងពិព័រណ៍ការងារ | ILO៖ គោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលចូលរួមនៅក្នុងប្រព័ន្ធអនុញ្ញាតិមុខរបរ នៃសាធារណរដ្ឋកូរ៉េ (ទីក្រុងបាងកក ឆ្នាំ២០១៥) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| **គោលការណ៍សេវាទេសន្តរប្រវេសន៍បែបវិមជ្ឈការ នៅកម្រិតមូលដ្ឋាន និងកម្រិតភូមិ៖ (P)-5.6; G-6.1.4; G-6.2** | ឥណ្ឌូណេស៊ី៖ ភូមិរបស់ពលករទេសន្តរប្រវេសក៍ (Desmigratif) | កម្មវិធីទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដែលអនុវត្តដោយក្រសួងហត្ថពលកម្មឥណ្ឌូណេស៊ី។ កម្មវិធីនេះផ្ដោតលើភូមិកំណើតរបស់ពលករទេសន្តរប្រវេសក៍ ដើម្បីផ្ដល់សេវាកាន់តែប្រសើរដល់អ្នកដែលមានបំណងចង់ធ្វើទេសន្តរប្រវេសន៍ គ្រួសាររបស់ពលករទេសន្តរប្រវេសក៍ និងពលករដែលបានធ្វើមាតុភូមិនិវត្តន៍តាមរយៈមជ្ឈមណ្ឌលសេវាទេសន្តរប្រវេសន៍ និងការគាំទ្រដល់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ និងគ្រួសាររបស់ពួកគេ ឧទាហរណ៍ កម្មវិធីអប់រំឪពុកម្ដាយនៅតាមសហគមន៍ (Community Parenting) ជាដើម។ | អាស៊ាន៖ កម្រងព័ត៌មានស្ដីពីកម្មវិធីអប់រំពលករទេសន្តរប្រវេសក៍ និងកម្មវិធីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព (ទីក្រុងហ្សាការតា លេខាធិការដ្ឋានអាស៊ាន ឆ្នាំ២០១៧) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | ហ្វីលីពីនៈ កម្មវិធី Assist WELL (សុខុមាលភាព ការងារ ច្បាប់ និង ជីវភាពរស់នៅ) | កម្មវិធី "Assist WELL" គឺជាកញ្ចប់ជំនួយសមាហរណកម្ម ដែលផ្តោតលើតម្រូវការសុខុមាលភាព តម្រូវការការងារ តម្រូវការផ្នែកច្បាប់ និងតម្រូវការជីវភាពរស់នៅរបស់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ | ក្រសួងការងារ និងមុខរបរ រដ្ឋាភិបាលហ្វីលីពីនៈ កម្មវិធី "Assist WELL (សុខុមាលភាព ការងារ ច្បាប់ និងជីវិភាពរស់-នៅ)" https://www.dole.gov.ph/assist- well-welfare-employment-legal-livelihood/ |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| **ស្ថាប័នដែលទទួលបន្ទុកសមាហរណកម្ម** G-6.1.1 | ហ្វីលីពីន៖ មជ្ឈមណ្ឌលជាតិសម្រាប់សមាហរណកម្ម (ពលករហ្វីលីពីនដែលធ្វើការនៅក្រៅប្រទេស) (NCRO) | បង្កើតឡើងនៅក្នុងឆ្នាំ២០០៧ បច្ចុប្បន្ន NCRO គឺជាទីភ្នាក់ងារមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋបាលសុខុមាលភាពពលករក្រៅប្រទេស នៃក្រសួងការងារ និងមុខរបរ សកម្មភាពនានាគ្របដណ្តប់លើ៖<br>• ការផ្តល់ប្រឹក្សាយោបល់<br>• ការជួយបញ្ជូនទៅរកការងារដែលបើកប្រាក់ឈ្នួល<br>• ការអភិវឌ្ឍសហគ្រាស<br>• ការបណ្តុះបណ្តាលជំនាញ និងការបង្កើនសមត្ថភាព និង<br>• ការផ្តល់ជំនួយដល់ពលករដែលជួបនឹងបញ្ហា<br>មជ្ឈមណ្ឌលនេះសហការជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម TESDA និងការិយាល័យធ្វើការងារក្រៅប្រទេសរបស់ហ្វីលីពីន | ក្រសួងការងារ និងមុខរបររបស់រដ្ឋាភិបាលហ្វីលីពីន៖ "សេវាសមាហរណកម្មសម្រាប់ពលករហ្វីលីពីននៅក្រៅប្រទេស" https://www.dole.gov.ph/reintegration-services-for-overseas-filipino-workers/ |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| **ការផ្តល់លិខិតបញ្ជាក់ជំនាញ និងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសក៍**<br>G-73 | ហ្វីលីពីន៖ អាជ្ញាធរអប់រំបច្ចេកទេស និងអភិវឌ្ឍន៍ជំនាញ (TESDA) កម្មវិធីវាយតម្លៃផ្ទាល់នៅនឹងកន្លែង (TOAP) ដាក់អនុវត្តនៅក្នុងឆ្នាំ២០១៥ | ស្ថាប័ននេះមានគោលបំណងផ្តល់ឱកាសដល់ពលករ ហ្វីលីពីនដែលធ្វើការនៅក្រៅប្រទេស (OFWs) ឱ្យទទួលបានលិខិតបញ្ជាក់ ឬការទទួលស្គាល់កម្រិតជំនាញបច្ចេកទេស និងចំណេះដឹងរបស់ពួកគេ។ គោលដៅតាមរយៈការផ្តល់លិខិតបញ្ជាក់នេះគឺ ផ្តល់លទ្ធភាពដល់ពលករហ្វីលីពីននៅក្រៅប្រទេសអាចរក្សានិងមានជីវភាពរស់នៅក៏ដូចជាអាជីពការងារកាន់តែប្រសើរ ទោះបីជានិយោជិតក្តី ឬជាសហគ្រិនក្តី តាមរយៈការផ្តល់លិខិតបញ្ជាក់។ TESDA ក៏ធ្វើការវាយតម្លៃនៅក្រៅប្រទេស ដោយសហការជាមួយនឹងអ្នកវាយតម្លៃ ដែលបានទទួលការបញ្ជាក់គុណភាពត្រឹមត្រូវផងដែរ។ | អាជ្ញាធរអប់រំបច្ចេកទេស និងអភិវឌ្ឍន៍ជំនាញ (TESDA) រដ្ឋាភិបាលហ្វីលីពីន "TESDA រៀបចំការវាយតម្លៃនៅនឹងកន្លែងសម្រាប់ពលករហ្វីលីពីននៅក្រៅប្រទេស" នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ http://www.tesda.gov.ph/News/Details/17644 |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| គោលការណ៍សាមគ្គីភាពសម្រាប់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ រាប់បញ្ចូលទាំងអ្នកដែលត្រូវបានគេបណ្តេញចេញ អ្នកដែលស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ និងពលករដែលត្រូវបានគេរំលោភបំពាន និងការផ្តល់សេវាសមាហរណកម្ម<br>P-5.2; P-5.3;<br>P-5.4; P-5.9; | ម៉ិកស៊ីកូ៖ Somos Mexi-canos (យើងជាជនជាតិម៉ិកស៊ីកូ) | នេះគឺជាកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិលើកទីមួយរបស់ម៉ិចស៊ីកូ ក្នុងការលើកកម្ពស់សមាហរណកម្មពលករដែលធ្វើមាតុភូមិនិវត្តន៍ ដោយប្រើប្រាស់អភិក្រមចម្រុះសម្រាប់សម្របសម្រួលសកម្មភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗ។ កម្មវិធីនេះផ្តល់សេវាដល់ពលករដែលបានធ្វើមាតុភូមិវត្តន៍ ក្រោយពេលដែលពួកគេមកដល់ក្នុងប្រទេស ដើម្បីធ្វើសមាហរណកម្ម និងអាចឱ្យពួកគេយកជំនាញដែលពួកគេបានទទួល ទៅប្រើប្រាស់។ កម្មវិធីនេះផ្តល់សេវាដូចតទៅ៖<br>• ការផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណ<br>• លិខិតបញ្ជាក់ពីគុណវុឌ្ឍិ ដែលទទួលបាននៅក្រៅប្រទេស<br>• ការបណ្តុះបណ្តាលជំនាញឡើងវិញ អត្ថប្រយោជន៍ផ្នែកសុខភាព | R. Dominguez-Villegas៖ "ការការពារ និងការធ្វើសមាហរណកម្ម៖ ម៉ិកស៊ីកូកែទម្រង់របៀបវារៈទេសន្ត-ប្រវេសន៍នៅក្នុងយុគសម័យដែលកាន់តែមានភាពស្មុគស្មាញ" ក្នុងប្រភពព័ត៌មានទេសន្តរប្រវេសន៍ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ https://www.migrationpolicy.org/article/ protection-and-reintegration-mexico- re-forms-migration-agenda |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | | • ព័ត៌មានអំពីការងារ និងផ្តល់ការងារតាមអនឡាញ និង<br>• ព័ត៌មានអំពីឱកាសវិនិយោគ<br>យុទ្ធសាស្ត្រ Somos Mexicanos ត្រូវបានអនុវត្តដោយការិយាល័យសម្របសម្រួលថ្នាក់ជាតិ និងរដ្ឋចំនួន ៣២ នៅទូទាំងប្រទេស។ យុទ្ធសាស្ត្រនេះ គឺជាកម្មវិធីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានបរិយាប័ន្ន (គ្របដណ្តប់លើពលករទេសន្តរប្រវេសក៍ទាំងអស់ ដោយមិនប្រកាន់ពីឋានៈរបស់ពួកគេឡើយ) | |
| | អេក្វាឌ័រ៖ កម្មវិធីស្វាគមន៍មកស្រុកកំណើត សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រ | ចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧ នេះជាយុទ្ធនាការដ៏ធំមួយ ដើម្បីផ្តល់សេវាដល់ជនជាតិអេក្វាឌ័រដែលធ្វើការនៅក្រៅប្រទេស។ យុទ្ធនាការនេះមានកម្មវិធីចំនួន ៣៖<br>១. កម្មវិធីតភ្ជាប់ទំនាក់ទំនង | B.D. Jokisch៖ "អេក្វាឌ័រ ចាប់ពីការនិប្រវេសន្តន៍ទ្រង់ទ្រាយធំ ទៅជាការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរ-ប្រវេសក៍?" នៅក្នុង |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
| --- | --- | --- | --- |
| | ចិត្ត ប្រកបដោយសេចក្តីថ្លៃថ្នូរ និងចីរភាព (Plan Bienvenid@s a Casa: Por un regreso voluntario, digno y sostenible) | ២. កម្មវិធីផ្តល់ការលើកទឹកចិត្ត និងការតម្រង់ទិស និង<br>៣. កម្មវិធីធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញ។<br>ចំណុចសំខាន់មួយ គឺថាកម្មវិធីនេះផ្តោតលើពលករទេសន្តរប្រវេសក៍ដែលកំពុងធ្វើការនៅក្រៅប្រទេសផង និងអ្នកដែលធ្វើមាតុភូមិនិវត្តន៍ផង។ កម្មវិធីទី ៣ សម្របសម្រួលផ្តល់ការគាំទ្រដល់ពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិ-និវត្តន៍ ដែលផ្តល់ដោយស្ថាប័នរដ្ឋាភិបាលជាង ៣០ ដូចជា ការចុះឈ្មោះ ការផ្តល់លិខិតបញ្ជាក់ និងការទទួលស្គាល់ជំនាញដែលពួកគេបានទទួលនៅក្រៅប្រទេស និងការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។ | ព័ត៌មានស្តីពីទេសន្តរប្រវេសក៍ ប្រភពថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ https://www.migrationpolicy.org/article/ecuador-mass-emigration-return-migration<br>S. Dolnickdec៖ "អេក្វាឌ័រព្យាយាមបញ្ចុះបញ្ចូលឱ្យពលកររបស់ខ្លួនវិលត្រឡប់មកស្រុកកំណើតវិញ" នៅក្នុងសារព័ត៌មាន The New York Times ថ្ងៃទី ២ ខែធ្នូ ឆ្នាំ២០១០ http://www.nytimes.com/2010/12/03/nyregion/03ecuador.html?_r=0 |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| **ការកែប្រែសមាសធាតុនៃគម្រោងសាកល្បងទៅជាក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត**<br>G-6.1.1 | Cabo Verde៖ មជ្ឈមណ្ឌលគាំទ្រពលករទេសន្តរ-ប្រវេសក៍នៅប្រទេសកំណើត (CAMPO) | CAMPO បានចាប់ផ្ដើមអនុវត្តក្នុងទម្រង់ជាគម្រោងសហប្រតិបត្តិការបច្ចេកទេសផ្នែកទេសន្តរប្រវេសន៍ ដើម្បីជំរុញឱ្យមានការធ្វើទេសន្តរប្រវេសន៍ច្បាប់រវាង Cabo Verde និងសហភាពអឺរ៉ុប តាមរយៈភាពជាដៃគូសម្រាប់លើកកម្ពស់ទេសន្តរប្រវេសន៍ ។ កម្មវិធីនេះសេវាផ្ដល់ប្រឹក្សាដោយមិនគិតថ្លៃដល់ប្រជាជនមកពី Cabo Verde ដែលគ្រោងធ្វើទេសន្តរប្រវេសន៍ ទៅសហភាពអឺរ៉ុប ជាពិសេសទៅប្រទេសព័រទុយហ្គាល់ និងព័ត៌មានអំពីសមាហរណកម្មដល់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ពីសហភាពអឺរ៉ុប។ លក្ខណៈនវានុវត្តន៍មួយគឺការបញ្ចូលមជ្ឈមណ្ឌលគាំទ្រពលករទេសន្តរប្រវេសក៍ CAMPO ទៅក្នុងរដ្ឋបាលការងារក្រៅប្រទេសស្របច្បាប់របស់ Cabo Verde នៅពេលចប់គម្រោង ដែលជួយ | IOM: "Cabo Verde", https://www.iom.int/countries/cabo-verde<br><br>A.C. Suh and F. Rodrigues: សៀវភៅណែនាំស្ដីពីការធ្វើសមាហរណកម្មរបស់អ្នកជំនាញផ្នែកសង្គមនៃ Cabo Verde មកពីប្រទេសហូឡង់ (ក្រសួងសហគមន៍ ពុំមានកាលបរិច្ឆេទ) https://www.diaspora-centre.org/wp-content/ uploads/2013/10/Manual-of-Reintegration- The-Netherlands-Cabo-Verde.pdf |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | | ជានាបាននូវនិរន្តរភាព។ ដោយសារតែចំនួនដែលធ្វើមាតុភូមិនិវត្តន៍ពីអឺរ៉ុបមានការកើនឡើងនាពេលថ្មីៗនេះ CAMPO កាន់តែមានភាពពាក់ព័ន្ធ និងផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងលើការធ្វើសមាហរណកម្ម និងការជំរុញឱ្យមានការចូលរួមពីអនិកជនដែលបានធ្វើមាតុភូមិនិវត្តន៍ទៅក្នុងការងារអភិវឌ្ឍន៍។ ចំណុចដែលល្អមួយទៀត គឺកម្មវិធីនេះបានទទួលការគាំទ្រពីដៃគូនៅក្នុងប្រទេសទាំងពីរ ( ព័រទុយហ្កាល់ និង Cabo Verde ) | |
| | អេត្យូពី៖ សារាចរណែនាំស្តីពីសមា-ហរណកម្មដែលបានទទួលការអនុម័តនៅថ្នាក់ | សារាចរណែនាំនេះបានដាក់ឱ្យអនុវត្តជាផ្លូវការនូវកញ្ចប់សមាហរណកម្មសាកល្បងផ្តោតលើជនរងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍។ សារាចរណែនាំនេះផ្តល់នូវមូលដ្ឋានច្បាប់ និងការណែនាំគ្រប់ជ្រុងជ្រោយ សម្រាប់រដ្ឋាភិបាលអេត្យូពី និងភាគី ពាក់ព័ន្ធដទៃទៀត ដែលធ្វើការងារពាក់ព័ន្ធ | D. Lindgren, T. Uaumnuay, K. Emmons: គម្រោងអង្កេតដើមគ្រោះ៖ ការកែលម្អអភិបាលកិច្ចទេសន្ត-ប្រវេសន៍ ការងារ ដើម្បីការពារពលករទេសន្តរប្រវេសក៍ និង |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
| --- | --- | --- | --- |
| | ក្រសួង ក្នុងខែកញ្ញា ឆ្នាំ២០១៨ | នឹងការធ្វើសមាហរណកម្មសម្រាប់ជនដែលត្រូវបានបង្ខំឱ្យធ្វើមាតុភូមិនិវត្តន៍ និងជនដែលបានធ្វើមាតុភូមិនិវត្តន៍ដទៃទៀតនៅក្នុងប្រទេសអេត្យូពី។ | ប្រយុទ្ធប្រឆាំងនឹងទេសន្តប្រវេសក៍ខុសច្បាប់នៅក្នុងប្រទេសអេត្យូពី (Addis Ababa, ILO, 2018). |
| | ព័រទុយហ្គាល់៖ ការបង់ប្រាក់ឱ្យពលករទេសន្តរប្រវេសក៍ធ្វើមាតុភូមិនិវត្តន៍ - កម្មវិធី Regressar (មាតុភូមិនិវត្តន៍) | រដ្ឋាភិបាល ព័រទុយហ្គាល់ បានគូសបញ្ជាក់ថាប្រទេសនេះស្វាគមន៍ដោយ "បើកចំហ" ចំពោះនិប្រវេសក៍ជនទាំងឡាយ។ ចំណុចដែលល្អគឺលក្ខណៈបរិយាបន្ននៃវិធានការនេះ ពោលគឺវិធានការនេះស្វាគមន៍ការធ្វើមាតុភូមិនិវត្តន៍មនុស្សគ្រប់ជំនាន់ និងគ្រប់វណ្ណៈទាំងអស់នៅក្នុងសង្គម ការឈានចូលវ័យចំណាស់របស់ប្រជាជន និងការថយចុះនូវចំនួនប្រជាជន និងការកើនឡើងនូវតម្រូវការពលករក្នុងវិស័យឧស្សាហកម្មនានា ជាកត្តាដែលជំរុញឱ្យមានការដាក់ចេញនូវគោលនយោបាយនេះ។ គោលនយោបាយនេះផ្តល់កត្តា | D. Elliot: "ព័រទុយហ្គាល់ ចង់ឱ្យនិប្រវេសជនរបស់ខ្លួនត្រឡប់មកវិញ - ដូច្នេះប្រទេសនេះផ្តល់ប្រាក់ ដើម្បីឱ្យពួកគេធ្វើមាតុភូមិនិវត្តន៍" ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ (វេទិកាសេដ្ឋកិច្ចពិភពលោក) https://www.weforum.org/agenda/2019/08/portugal-emigration-incentives-population/ សារព័ត៌មាន ព័រទុយហ្គាល់៖ |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | | លើកទឹកចិត្តជាច្រើន ដូចជា ការលើកលែងពន្ធ និងសាច់ប្រាក់ឧបត្ថម្ភសម្រាប់ការផ្លាស់ប្តូរទីលំនៅជាដើម។ | "ព័រទុយហ្គាល់ ស្វាគមន៍និប្រវេសជនដែលធ្វើមាតុភូមិនិវត្តន៍ "ដោយបើកចំហ" ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ https://www.theportugalnews.com/news/portugal- welcomes-all-returning-emigrants-with- open-arms/49853<br>សារព័ត៌មាន The Economist " ព័រទុយហ្គាល់ ព្យាយាមបញ្ចុះបញ្ចូលនិប្រវេសជនឱ្យវិលត្រឡប់មកវិញ" ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩<br>www.economist.com/finance-and-economics/2019/08/01/portugal-tries-to-lure-emigrants-back |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| លទ្ធផលដែលបានពីការស្រាវជ្រាវអំពីការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសក៍ត្រូវបានប្រើប្រាស់នៅក្នុងការរៀបចំផែនការគោលនយោបាយ<br>P-5.1.1; G-6.1.3 | វេទិកាសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការអភិវឌ្ឍ (RDP), គម្រោងនៃសកលវិទ្យាល័យ Florence | នេះគឺជាការស្រាវជ្រាវនាំមុខមួយ ផ្តោតលើពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយប្រើប្រាស់លទ្ធផលសិក្សានៅក្នុងប្រទេស Maghreb (អាល់ហ្សេរី ម៉ារ៉ុក និង ទុយនីស៊ី)។ គោលបំណងចម្បងនៃគម្រោងនេះ គឺដើម្បីឈ្វេងយល់ពីបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការធ្វើមាតុ-ភូមិនិវត្តន៍ និងផលប៉ះពាល់មកលើការអភិវឌ្ឍ។ វេទិកាមាតុភូមិនិវត្តន៍ និងការអភិវឌ្ឍ (RDP) ប្រើប្រាស់អភិក្រមពីលើមកក្រោមផង និងពីក្រោមឡើងលើផង សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម។ នេះគឺជាវេទិកាសម្រាប់ធ្វើការផ្លោះប្តូរ និងចែករំលែកចំណេះដឹង អំពីស្ថានភាពពិតប្រាកដរបស់ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍។ | J.-P. Cassarino (ed.): សមាហរណកម្ម និងការអភិវឌ្ឍ (មជ្ឈមណ្ឌល Florence, Robert Schuman Centre សម្រាប់ការសិក្សាជាន់ខ្ពស់ វិទ្យាស្ថានសាកលវិទ្យាល័យអឺរ៉ុប ឆ្នាំ២០១៤) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | បង់ក្លាដែស៖ ការអង្កេតលើពលករទេសន្តរប្រវេសក៍បង់ក្លាដែស ដែលបានធ្វើមាតុភូមិនិវត្តន៍ ឆ្នាំ២០១៥។ | គំនិតផ្តួចផ្តើមសហប្រតិបត្តិការរវាងក្រសួងសុខុមាលភាពពលករទេសន្តរប្រវេសក៍ និងការងារក្រៅប្រទេស (MEWOE) ជាមួយនឹងដៃគូសង្គមនានា ដូចជាវិទ្យាស្ថានសិក្សាពីការងាររបស់បង់ក្លាដែស (BILS) និង ILO បានធ្វើការវាយតម្លៃលើជំនាញ និងតម្រូវការសហគ្រិនភាពនៅក្នុងសេដ្ឋកិច្ចនៅក្នុងប្រទេសបង់ក្លាដែស ដើម្បីធ្វើសមាហរណកម្មពលករទៅក្នុងទីផ្សារការងារប្រកបដោយប្រសិទ្ធភាព។ លទ្ធផលដែលល្អនៃការសិក្សានេះ គឺគំនិតផ្តួចផ្តើមអនុវត្តដោយសហព័ន្ធនិយោជកបង់ក្លាដែស (BEF) ដើម្បីបង្កើតនូវការិយាល័យផ្តល់ជំនួយមួយដែលមានឈ្មោះថា Help Desk Bangladesh សម្រាប់ជួយគាំទ្រដល់អ្នកដែលបានធ្វើមាតុភូមិនិវត្តន៍ឱ្យអាចធ្វើសមាហរណកម្មមកក្នុងសកម្មភាពសេដ្ឋកិច្ចវិញ។ | S.R. Rashid and A.A. Ashraf: ក្របខ័ណ្ឌសេវាសម្រាប់សមាហរណកម្ម និងការធ្វើទេសន្តប្រវេសក៍ជាថ្មីរបស់ពលករទេសន្តរប្រវេសក៍អន្តរជាតិ ដែលមានប្រភពពីប្រទេសបង់ក្លាដែស (Dhaka, IOM, 2018) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | ប្រព័ន្ធព័ត៌មាន ATIS នៃក្រុមប្រឹក្សាសហជីពអាស៊ាន (ATUC) សម្រាប់ពលករទេសន្តរ-ប្រវេសក៍ | ATIS គឺជាយន្តការបណ្តឹងអនឡាញ និងប្រព័ន្ធបញ្ជូនដែលអនុវត្តដោយ ATUC ក្រោមជំនួយរបស់ ILO។ យន្តការនេះទទួលបណ្តឹង និងបញ្ជូនបណ្តឹងទៅកាន់ភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ និងដៃគូ ATUC ដើម្បីចាត់វិធានការ។ | R. Mapalo: "ឆ្ពោះទៅកាន់ការងារសមរម្យសម្រាប់ពលករទេសន្តរប្រវេសក៍៖ គំនិតផ្តួចផ្តើមរបស់ ATUC" បទបង្ហាញ https://actrav-courses.itcilo. org/en/a3-58344/a3-58344-presentations/decent-work-for-migrant-workers-atuc- initia-tive/at_download/file |
| **ផ្តោតគោលដៅលើពលករទេសន្តរប្រវេសក៍ដែលបានធ្វើមាតុភូមិ-និវត្តន៍ P-5.5; P-5.4; P-5.11; G-6.1.4; G-6.3** | ហ្វីលីពីន៖ Balik Pinay! Balik Hanapbuhay (កម្មវិធីពិសេសសម្រាប់ពលករទេសន្តរប្រវេសក៍ | អន្តរាគមន៍បណ្តុះបណ្តាល និងផលិតកម្ម/ការងារដែលមានគោលបំណងលើកកម្ពស់សុខុមាលភាពសង្គមសេដ្ឋកិច្ចរបស់ពលករទេសន្តរប្រវេសក៍ជាស្ត្រីជនជាតិហ្វីលីពីន ដែលបានធ្វើមាតុភូមិនិវត្តន៍។ ផ្តល់នូវកញ្ចប់គាំទ្រ/ជំនួយសម្រាប់លើកកម្ពស់មុខរបរចិញ្ចឹមជីវិត ដើម្បីផ្តល់ការសង្គ្រោះបន្ទាន់ ដល់ | អាស៊ាន៖ កម្រងព័ត៌មានស្តីពីកម្មវិធីអប់រំពលករទេសន្តរ-ប្រវេសក៍ និងកម្មវិធីទេសន្តរ-ប្រវេសន៍ ប្រកបដោយសុវត្ថិភាព (ទីក្រុងចាកាតាលេខាធិការ-ដ្ឋានអាស៊ាន ឆ្នាំ២០១៧) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | ជាស្ត្រីដែលបាន ធ្វើមាតុភូមិនិវត្តន៍ ប្រទេសហ្វីលីពីន ) | ពលករទេសន្តរប្រវេសក៍ជនជាតិហ្វីលីពីនដែល បានធ្វើមាតុភូមិនិវត្តន៍ (ជួបបញ្ហា/បាត់បង់ទីលំនៅ) ក្នុងចំនួនទឹកប្រាក់ច្រើនបំផុត ២០,០០០.០០០ ប៉េសូ ជាថវិកាសម្រាប់ចាប់ផ្តើម ឬជាទុនបន្ថែម សម្រាប់គម្រោងប្រកបមុខរបរចិញ្ចឹមជីវិត។ | |
| **គោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសក៍** G-6.1.1; G-VIII | គោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការធ្វើមាតុភូមិ-និវត្តន៍ និងសមាហ-រណកម្មពលករទេសន្តរប្រវេសក៍ដែលបានចូលរួមនៅក្នុងកម្មវិធី EPS របស់សាធារណរដ្ឋ | មានគោលបំណងដាក់ចេញនូវក្របខ័ណ្ឌសម្រាប់ប្រទេសបញ្ជូនដែលចូលរួមកម្មវិធី EPS ជុំវិញការឆ្លើយតបគោលនយោបាយ យន្តការស្ថាប័ន និងកម្មវិធី ឬសេវាដែលចាំបាច់ ដើម្បីឱ្យពលករទេសន្ត-ប្រវេសក៍អាចធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយជោគជ័យ។<br>គោលការណ៍ណែនាំនេះគ្របដណ្តប់លើវដ្តនៃទេសន្តរប្រវេសន៍ បណ្តោះអាសន្នទាំងស្រុង ចាប់ពីមុនពេលចេញដំណើរ ពេលធ្វើការនៅក្រៅប្រទេស ពេលធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ | ILO: គោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពលករទេសន្តរប្រវេសក៍ដែលចូលរួមនៅក្នុងប្រព័ន្ធអនុញ្ញាតការងារនៃសាធារណរដ្ឋកូរ៉េ (ទីក្រុងបាងកក ឆ្នាំ២០១៥) |

| ប្រភេទនៃការអនុវត្តល្អ | ឧទាហរណ៍ | ចំណុចសំខាន់ៗ | ប្រភព |
|---|---|---|---|
| | កូរ៉េ ចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១៥ | ជម្រើសនាពេលអនាគតសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ (ចាប់ផ្តើមអាជីវកម្ម សន្សំប្រាក់ និងវិនិយោគ ។ល។) ត្រូវបានបញ្ចូលចាប់ពីដំណាក់កាលតម្រង់ទិសមុនពេលចេញដំណើរ។ ការិយាល័យសម្របសម្រួលថ្នាក់ជាតិនៅក្នុងប្រទេសប្រភពដើម និងប្រព័ន្ធទិន្នន័យពលករ EPS គឺជាលក្ខខណ្ឌទុកជាមុនសម្រាប់កម្មវិធីនេះ ។ ប៉ុន្តែការពិនិត្យតាមដានលើកម្មវិធីនេះនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ | |

សម្គាល់៖ ឯកសារយោងដែលពាក់ព័ន្ធនឹងគោលការណ៍ណែនាំទូទៅ (P-) និងគោលការណ៍ណែនាំ (G-) ត្រូវបានលើកឡើងក្រោមការអនុវត្តល្អនីមួយៗទៅតាមការពាក់ព័ន្ធ។ ព័ត៌មានលម្អិតបន្ថែម អាចរកបាននៅក្នុងឯកសារ៖ P. Wickramasekara៖ ការវិលត្រឡប់ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើរដ្ឋជាសមាជិកអាស៊ាន (ទីក្រុងបាងកក ILO ឆ្នាំ ២០១៩)។

ASEAN: A Community of Opportunities for All

ASEAN

ASEAN

@ASEAN

www.asean.org